FARMING GOD'S WAY

# កសិកម្មតាមរបៀបព្រះជាម្ចាស់

## សេចក្តីណែនាំសម្រាប់អនុវត្តន៍ លើដីចម្ការ



# កសិកម្មតាមរបៀបព្រះជាម្ចាស់


សង្ខេបខ្លីៗ ........ ១

គន្លឹះនៃព្រះគម្ពីរ ........ ៤

គន្លឹះទី ១ ការទទួលស្គាល់ព្រះ និង ជឿលើទ្រង់តែមួយគត់ ........ ៥

គន្លឹះទី ២ ការពិចារណានូវរបៀបរបស់អ្នក ........ ៨

គន្លឹះទី ៣ ការស្វែងយល់ពីភាពបរិបូរណ៌របស់ព្រះជាម្ចាស់ ........ ១០

គន្លឹះទី ៤ អ្នកប្រមូលផលនូវអ្វីដែលអ្នកសាបព្រោះ ........ ១៣

គន្លឹះទី ៥ ការនាំផង្វាយ និង ផង្វាយមួយភាគដប់មកកាន់ព្រះជាម្ចាស់ ........ ១៥

គន្លឹះទី ៦ ទាមទារអ្វីដែលជារបស់អ្នក ........ ១៧

ដំណាក់កាលតាមលំដាប់លំដោយ ........ ១៩

មូលហេតុទាំង ២០ ដែលយើងត្រូវធ្វើតាមរបៀបរបស់ព្រះជាម្ចាស់ ........ ៣០

ការគ្រប់គ្រង ........ ៣៨

គន្លឹះទី ១ ការធ្វើអោយទាន់ពេលវេលា ........ ៣៨

គន្លឹះទី ២ ដំណើរទៅរក ស្តង់ដារខ្ពស់ ........ ៣៩

គន្លឹះទី ៣ មិនត្រូវខ្ជះខ្ជាយឡើយ ........ ៤០

សេចក្តីសន្និដ្ឋាន ........ ៤២

ការធ្វើជីកំប៉ុស្តិ៍ ........ ៤៣

ជីវៈចម្រុះតាមប្រភេទដំណាំខុសៗគ្នា ........ ៤៩

សេចក្តីបន្ថែម ........ ៥៣

ប្រភពធនធាន ........ ៥៧

# សង្ខេបខ្លីៗ

**កសិកម្មតាមរបៀបរបស់ព្រះជាម្ចាស់**

**ការរៀបចំអោយកសិករមានជីវិតពេញបរិបូរណ៍ក្នុងព្រះយេស៊ូ**

*នៅទ្វីបអាហ្វ្រិចមានធនធានធម្មជាតិច្រើនជាងទ្វីបណាៗទាំងអស់ នៅក្នុងសកលលោក។ ទ្វីបនេះគឺពោរពេញទៅដោយ រ៉ែគ្រប់ប្រភេទ រ៉ែដែក ប្រេង សក្តានុពលខាងផ្នែកកសិកម្មដ៏ប្រសើរ ហើយធនធានមនុស្សក៏មានច្រើន ព្រមទាំងប្រភពទឹកផងដែរ។ អ្វីម្យ៉ាងដែលគួរចាប់អារម្មណ៍ទៅទៀតនោះគឺ ជីវះចម្រុះដែលមាននៅក្នុងព្រៃយ៉ាងសន្ធឹកសន្ធាប់ផ្សេងៗទៀត ដែលអាចទាក់ទាញភ្ញៀវទេសចរណ៍ជាច្រើនមកទស្សនាទៀតផង។*

*តែផ្ទុយទៅវិញ ទ្វីបអាហ្វ្រិចគឺជួបប្រទះនិងភាពក្រីក្រយ៉ាងខ្លាំង។ ប្រជាជនមានជីវភាពតោគយ៉ាក មានគ្រោះទុរភិក្ស មនុស្សខ្វះអាហារបរិភោគគ្រប់គ្រាន់ អត្រាមរណៈរបស់កុមារខ្ពស់ ជម្ងឺ សង្គ្រាម រស់ពឹងលើប្រទេសដ៏ទៃ ការអប់រំគ្មានគុណភាព ការកាប់បំផ្លាញព្រៃឈើ អំពើពុករលួយ ហើយនិងមានអតិផលរណាកើនឡើងយ៉ាងខ្ពស់។*

*ប្រហែលជា ៨៥% នៃកសិករគឺមានជីវិតរកមួយថ្ងៃហូបមួយថ្ងៃ ហើយពួកគេមានស្ថានភាពស្គមស្គាំង ជីវភាពពិតជាមានការតោកយ៉ាកយ៉ាងខ្លាំង។ ទិនផលគឺមានចំនួនតិចជាងអ្វីដែលពួកគេត្រូវការក្នុងគ្រួសារ ដែលជាហេតុនាំអោយមានការនាំចូលស្បៀងអាហាររាប់លានតោនជារៀងរាល់ឆ្នាំ។*

***កសិករតាមរបៀបរបស់ព្រះជាម្ចាស់*** គឺជាដំណោះស្រាយជួយដល់កសិករក្រីក្រនៅតាមទីជនបទអោយមានសុវត្ថិភាពស្បៀងអាហារ និង ងាកចេញពីវិបត្តិនៃភាពក្រីក្រ។

***កសិកម្មតាមរបៀបរបស់ព្រះជាម្ចាស់*** គឺមិនមែនគ្រាន់តែជាការបណ្តុះ បណ្តាលខាងផ្នែកបច្ចេកទេសប៉ុណ្ណោះទេ ក៏ប៉ុន្តែវាមានការរួមបញ្ចូលអោយមានភាពស្មើរគ្នារវាងគោលការណ៍ទាំងបីគឺ ***ព្រះគម្ពីរ ការគ្រប់គ្រង*** និង ***បច្ចេកទេស*** ក្នុងការធ្វើកសិកម្ម ដើម្បីបំពាក់បំប៉នកសិករអោយងាកចេញពីភាពក្រីក្រ ហើយដើម្បីអោយពួកគេអាចធ្វើវាជាមួយនឹងអ្វីដែលព្រះជាម្ចាស់បានដាក់ក្នុងដៃពួកគេ ហើយក៏ដើម្បីអោយមនុស្សបានឃើញពីជីវិតពេញបរិបូរណ៌ពេញលេញ ដែលព្រះបានសន្យាថានឹងប្រទានអោយមនុស្សដែលនៅលើផែនដីនេះ។




តាមរយៈព្រះយេស៊ូ កសិករទទួលការផ្លាស់ប្រែក្នុងដួងចិត្ត ហើយនាំអោយមានការផ្លាស់ប្រែរបៀបនៃការគិត និងរបៀបនៃការគ្រប់គ្រង។ ហើយបន្ទាប់មកគឺការអនុវត្តកិច្ចការងារក្នុងការស្តារឡើងវិញទៅលើដីចម្ការរបស់ពួកគេ។

***កសិកម្មតាមរបៀបរបស់ព្រះ*** គឺត្រូវបានគេកត់ត្រាពីភាពជោគជ័យតាំងពីឆ្នាំ ១៩៨៤ នៅចម្ការរបស់លោក ***ប្រ៊ាយអ៊ីន អ៊ុលឌ្រីវ*** (Brian Oldreive) នៅប្រទេស ***ហ្ស៊ីម***

***ប៉ាវ៉េ*** នៃរដ្ឋ ***ហ៊ីនថុន*** ជាកន្លែងដែលលោកចាប់ផ្ដើមនៅការអនុវត្តកសិកម្មតាមរបៀបរបស់ព្រះ ដំបូងគេបង្អួស់នៅលើកសិដ្ឋានដ៏ធំ ហើយគាត់អាចច្រូតផលបា រហូតដល់ ៣៥០០ ហិចតា។

តាំងពីថ្ងៃនោះមក **កសិកម្មតាមរបៀបរបស់ព្រះជាម្ចាស់** បានរីករាលដាលទៅកាន់ប្រទេសជាច្រើនជុំវិញពីភពលោក ក្នុងក្រុមជំនុំ បេសកកម្ម និងអង្គការ ហើយនិងបណ្ដាលទ្វីបនានទូទាំងពិភពលោក។ នៅក្នុងឆ្នាំ ២០០៩ **កសិកម្មតាមរបៀបរបស់ព្រះជាម្ចាស់** បានពង្រីកដល់ប្រទេស *អង់គូឡា, បេនីន, ឌីអស៊ី, អេត្យូពី, ខេនយ៉ា លេសូតូ, ម៉ាដាកាសកា, ម៉ាវ៉ាលី, ម៉ូហ្សូមប៊ិច, ណាមីបៀ, នីហ្សេរីយ៉ា រីវ៉ានដា, ស៊ីរៀលេអន, អាព្រិចខាងត្បូង, ស្វីហ្សាឡាន, តង់ហ្សានៀ, យ៉ូហ្គានដា, ហ្សមបៀ, ហ្ស៊ីមប៉ាវេ* ហើយនិងប្រទេសដ៏ទៃទៀតក្នុង **ទ្វីបអាព្រិច** រហូតដល់ប្រទេស *ម៉ិចស៊ីកូ, នេប៉ាល់, កេនយ៉ានា អង់គ្លេស, សហរដ្ឋអាមេរិច, អង់គ្លេស* និង ប្រទេសដ៏ទៃទៀតផងដែរ។

**កសិកម្មតាមរបៀបរបស់ព្រះជាម្ចាស់** គឺជាការដូរមួយ ដ៏ឥតគិតថ្លៃរបស់ព្រះកាយរបស់ព្រះយេស៊ូគ្រីស្ទ ហើយក៏មិនប្រកាន់និកាយ អង្គការឬក្រុមមនុស្សណានោះទេ អោយតែធ្វើក្នុងប្រយោជន៍ជួយដល់អ្នកក្រីក្រ។ **កសិកម្មតាមរបៀបរបស់ព្រះជាម្ចាស់** គឺត្រូវបានផ្ដល់ដោយក្រុមអ្នករ៉ាប់រងរៀមច្បងស្ម័គ្រចិត្តក្នុងការធ្វើ ហើយក៏ជាអ្នកមានបទពិសោធន៍ត្រឹមត្រូវ ភាពថ្លៃថ្នូ រហូតអាចសម្រេចបានការងារល្អ ក៏ដូចជាយុទ្ធសាស្ត្រក្នុងកិច្ចការងារយ៉ាងល្អបំផុត។

គោលការណ៍នៃអ្នករ៉ាប់រងគឺជាគោលការណ៍មួយដែលអាច ជួយអោយមានការធានាអោយមានការចែករំលែកគម្រោងនេះដោយមានចិត្តសប្បុរសក្នុងការផ្លាស់ប្រែជីវិតបងប្អូនក្រីក្ររបស់យើង។

ព្រះបន្ទូលរបស់ព្រះជាម្ចាស់បានចែងថា **ត្បិតប្រជារាស្ត្ររបស់យើងក្រ ដោយសារតែគេខ្វះនូវចំណេះដឹង។** យើងត្រូវទទួលស្គាល់ពីសារៈសំខាន់នៃការបង្រៀនអ្នកក្រ អោយមានភាពស្មោះត្រង់ក្នុងកិច្ចការងារកសិកម្មរបស់ពួកគេមុននិង សក្ដានុពលក្នុងទ្វីបដ៏ធំនេះត្រូវបានសម្ដែងចេញ។

# គន្លឹះនៃព្រះគម្ពីរ

**គ្មានបច្ចេកវិទ្យាណាមួយអាចបំបែក**
**បណ្តាសានៃភាពក្រីក្រក្នុងទ្វីបដ៏ធំនេះបានទេ**
**យើងចាំបាច់ត្រូវអនុវត្តតាំងព្រះបន្ទូល និង សកម្មភាព**

ព្រះបន្ទូលរបស់ព្រះគឺជាអំណាចមួយដ៏អស្ចារ្យសម្រាប់សេចក្តីពិត ដើម្បីអោយយើងដើរតាមហើយការងាកមករកព្រះបន្ទូលរបស់ទ្រង់ គឺនាំមកនូវការបើកសម្តែង និងការនាំផ្លូវអោយឃើញពីនឹមដ៏សំខាន់ ហើយវាជានឹមខាង ព្រលឹងវិញ្ញាណ។ ប្រសិនជាយើងប្រើប្រាស់តែ**បច្ចេកទេស** និង **ការគ្រប់គ្រង**តែប៉ុណ្ណឹង នោះគឺមិនអាចជួយរំដោះអ្នកក្រីក្រអោយមានសេរីភាពបាននោះទេ។

- ហូសេ ៤ ៖ ១-៣
- ទំនុកតម្កើង ១០៧ ៖ ៣៣-៣៤
- យេរេមា ២៣ ៖ ១០

គន្លឹះព្រះគម្ពីទាំង ៦ នឹងបើកបង្ហាញពីភាពអាថ៌កំបាំងថាតើហេតុអ្វីបានជាទ្វីបអាព្រិចស្ថិតក្រោមនឹមនៃភាពក្រីក្រ ហើយផ្នែកនេះក៏នឹងប្រាប់ពីដំណោះស្រាយរបស់ទ្រង់ក្នុងការបំបែកនូវនឹមទាំងនេះ។

## គន្លឹះទីមួយ៖ ការទទួលស្គាល់ព្រះ និង ជឿលើទ្រង់តែមួយគត់

<u>**បញ្ហា៖**</u> *ប្រជាជនដែលរស់នៅក្នុងទ្វីបអាព្រិច គឺមានបន្ទាយដ៏ធំខាងព្រលឹង វិញ្ញាណនៃអំពើធ្មប់ និង ការគោរពវិញ្ញាណដូនតា។ គ្រូមន្តអាគមន៍ និង មេធ្មប់គឺមានស្ទើរតែគ្រប់ក្នុងភូមិស្រុករបស់ពួកគេ។ អ្នកស្រុកភាគច្រើនតែងតែទៅរក ពួកនេះដើម្បីជួយពួកគេ ដូចជា៖* ***ពេលមានជម្ងឺ ពេលចង់បានកូន បញ្ហាយុវជន ការកាត់ស្បែក ការរៀបការ*** *និង* ***ពិធីបុណ្យសព*** *។ អ្នកភូមិក៏មានទម្លាប់អញ្ជើញ គ្រូធ្មប់មកសូត្រលើដីចម្ការ របស់ពួកគេអោយទទួលផលច្រើនលើសលប់។ គ្រូមន្តអាគមន៍ ក៏ដូចជាគ្រូធ្មប់ធ្វើពីធីបួងសួងដោយមានការសែន មាន់ ព្រួសឈាមសត្វ បោះឆ្អឹង ការដាក់ឆ្អឹងក្បាលសត្វនៅលើឈើបង្គោលចម្ការពោតរបស់គេជាដើម។*

*ការថ្វាយបង្គំដូនតាគឺដើម្បីឧទ្ទិសទៅដល់វិញ្ញាណដែលស្លាប់ទៅហើយ តាមរយៈការសែននៅក្នុងពីធីបុណ្យទៅតាមទំនៀមទំលាប់ ការស្បថស្បែផ្សេងៗ។ ចូរចាំថាទង្វើរទាំងនេះគឺមិនមែនចេញពីសេចក្ដីស្រលាញ់នោះទេ តែផ្ទុយទៅវិញគឺចេញពីភាពភ័យខ្លាច ការញ័ររន្ធត់ទៅវិញ។*

- 📖 *អេសាយ ៨៖១៩-២២*
- 📖 *លេវីវិន័យ ១៩៖៣១*
- 📖 *ទុតិយកថា ១៨៖១០*
- 📖 *ទុតិយកថា ៥៖៧-៨*
- 📖 *ម៉ាថាយ ៦៖២៤*
- 📖 *ទំនុកតម្កើង ២៤៖៣*

<u>**ដំណោះស្រាយ**</u>*៖ គឺមានព្រះអង្គម្ចាស់តែមួយគត់ ហើយយើងទៅកាន់ទ្រង់បានតាមរយៈព្រះបុត្រារបស់ព្រះអង្គ គឺ* ***ព្រះយេស៊ូគ្រិស្ទ*** *ដែលទ្រង់បានសុគតនៅលើឈើឆ្កាងសម្រាប់យើង ដើម្បីអោយយើងទទួលបានការដូរដោយឥតគិតថ្លៃគឺជាជីវិតដ៏អស់*

*កលជានិច្ច។ ឥលូវនេះគឺយើងលែងរស់ក្នុងរបៀបនៃប្រព័ន្ធលោកកីយ៍ និងទំនៀមទម្លាប់នេះទៀតហើយ តែយើងត្រូវបានព្រះជាម្ចាស់ទទួលយកយើងធ្វើជាបុត្រធីតាក្នុងក្រុមគ្រួសាររបស់ព្រះ ហើយយើងក៏មានអភ័យឯកសិទ្ធដែលបានទទួលស្គាល់ព្រះអង្គជាព្រះបិតារបស់យើងផងដែរ។*

*យើងត្រូវងាកមកគោរពថ្វាយបង្គំព្រះជាម្ចាស់តែមួយប៉ុណ្ណោះក្នុងគ្រប់ផ្នែកទាំងអស់នៃជីវិតរបស់យើង គឺមិនមែនគ្រាន់តែក្នុងកម្មវិធីថ្ងៃអាទិត្យប៉ុណ្ណោះទេ។ មនុស្សមិនគួរបង្អាប់ព្រះកិត្តិនាមទ្រង់ទេ។*

> *សុភាសិត ៣៖ ៥-៦*
> *ត្រូវទុកចិត្តលើព្រះក្នុងគ្រប់ទាំងកិច្ចការទាំងអស់ដែលកូនធ្វើ*
> *កុំពឹងលើការចេះដឹងរបស់ខ្លួនឡើយ។ ក្នុងគ្រប់កិច្ចការដែលកូនធ្វើ*
> *ត្រូវនឹកដល់ទ្រង់ នោះទ្រង់និងត្រួសត្រាយផ្លូវកូន*

*នៅក្នុងខគម្ពីនេះ គឺបានណែនាំយើងអោយអាចធ្វើការទម្លុះទម្លាយបាន*

### *ត្រូវទុកចិត្តព្រះអោយអស់ពីចិត្តរបស់យើង*

*អស់អ្នកដែលទុកចិត្តយើង យើងនិងជួយគេ*

### *កុំពឹងលើការចេះដឹងរបស់ខ្លួនឡើយ*

*ព្រះយេស៊ូបានបំពេញកិច្ចការដែលទ្រង់ត្រូវធ្វើ ហើយទ្រង់មិនធ្វើដោយខ្លួនឯងនោះទេក៏ប៉ុន្តែទ្រង់ពឹងលើព្រះវបិតា។ ព្រះវបិតាបានបង្ហាញអ្វីដែលទ្រង់ត្រូវធ្វើហើយព្រះយេស៊ូបានធ្វើ ហើយទ្រង់ក៏ទទួលបានជោគជ័យ។*

- 📖 *យ៉ូហាន ៨ ៖ ២៨*
- 📖 *យ៉ូហាន ៨ ៖ ៣៨*
- 📖 *យ៉ូហាន ៥ ៖ ១៩*

*តើជីវិតរបស់យើងនិងចំរុងចំរើនយ៉ាងណា ប្រសិនជាយើងរស់នៅស្របតាមព្រះហរទ័យរបស់ទ្រង់?*

### *ត្រូវនឹកចាំដល់ទ្រង់ ក្នុងគ្រប់កិច្ចការទាំងអស់ដែលកូនធ្វើ*

*នៅគ្រប់ទាំងកិច្ចការទាំងអស់របស់យើងគឺមានន័យថា គ្រប់ទាំងផ្នែករបស់យើង រួមទាំងការងារ ពាក្យសម្តី សកម្មភាព និង ចិត្តគំនិត របស់យើង។ ដោយហេតុនេះហើយបានជាយើងត្រូវទទួលស្គាល់ទ្រង់តាំងតែពីយើងនៅតូច មកដល់ពេលពេញវ័យឡើង ពេលយើងរៀបអាពាហ៍ពិពាហ៍ ពេលធ្វើពិធីបុណ្យសព ពេលឈឺ ពេលមុនស្ទូង ពេលខែភ្លៀងធ្លាក់ ពេលច្រូតផល គឺត្រូវនឹកចាំព្រះអង្គក្នុងគ្រប់អ្វីៗទាំងអស់ដែលយើងធ្វើ។*

### *ហើយទ្រង់និង ត្រួសត្រាយផ្លូវរបស់យើងអោយត្រង់*

*មនុស្សដែលរស់នៅក្នុងទ្វីបអាព្រិច គឺពិតជាត្រូវការព្រះជាម្ចាស់តម្រង់ផ្លូវដែលខ្វះក្តីសង្ឃឹម និង ផ្លូវដែលមិនត្រូវរបស់ពួកគេណាស់។ ផ្លូវនេះតែងតែនាំមនុស្សអោយមានការវង្វេង។ ការតម្រង់ផ្លូវរបស់ព្រះជាម្ចាស់ និងបានដឹកនាំគេចូលទៅកាន់ជីវិតដ៏ពេញបរិបូរណ៍ដែលព្រះបានសន្យា។*

- 📖 ទុតិយកថា ១៨ ៖ ១៨
- 📖 ទុតិយកថា ៧ ៖ ១៣-១៥

*ប្រសិនជាយើងជឿថាវាគឺ ដល់ពេលវេលារបស់ទ្វីបអាព្រិចហើយ ដើម្បីងាកមករកព្រះនោះគឺយើងត្រូវ បំផ្លាញចោលអោយអស់នូវ ទីកន្លែងគោរពថ្វាយបង្គំព្រះក្លែងក្លាយ ហើយនិងបោះបង់ចោលនូវ អំពើឆ្មប់ទាំងឡាយណាដែលវាបានចងយើង។ ហើយបន្ទាប់ពីយើងធ្វើការនេះ រួចមកទើយើងអាចចូលទៅកាន់ព្រះជាម្ចាស់ជាមួយចិត្តដ៏បរិសិទ្ធ និងដៃស្អាតបាត ដើម្បីថ្វាយបង្គំទ្រង់តែមួយ ដោយវិញ្ញាណ និង សេចក្តីពិត។*

## គន្លឹះទី ២ ការពិចារណានូវរបៀបរបស់អ្នក

<u>**បញ្ហា៖**</u> ព្រះដំណាក់ព្រះជាម្ចាស់នៅក្នុងយើងគឺមានការបាក់បែកដោយសារតែ យើងបានបម្រើតែមហិច្ឆិតាអាត្មានិយម និងរបៀបដែលគ្មានប្រយោជន៍របស់យើង ហើយយើងបានដើរចេញពីមាគ៌ារបស់ព្រះជាម្ចាស់។ ប្រសិនជាយើង ដែលជាបុត្រធីតារបស់ព្រះជាម្ចាស់ គឺជាតំណាក់របស់ទ្រង់នោះយើងត្រូវចេះពិចារណាអំពីគុណភាពនៃព្រះដំណាក់របស់ទ្រង់ក្នុងជីវិតរបស់យើង។

យើងត្រូវតែគិតពិចារណាពីរបៀបរបស់យើង

ក្នុងកណ្ឌគម្ពីរ **ហាកាយ** ជំពូកទី ១៖២-១១ **ចូរគិតពីសភាពការណ៍របស់អ្នករាល់គ្នា ______ដំណាក់របស់យើងនៅបាក់បែកនៅឡើយ។**

បណ្តាសារមួយចំនួនដែលយើងមានគឺមកពីរបៀបរស់នៅរបស់យើងគឺមិនស្រប តាមរបៀបរបស់ព្រះជាម្ចាស់។

### ក) បណ្តាសា បង្ហូរឈាម និងអំពើហិង្សា

- រឿងរ៉ាវរបស់លោក **កាអ៊ីន** និង **អេបិល**
- មានរឿងរ៉ាវជាច្រើនទៀតដែលបានកើតឡើងនៅក្នុងទ្វីបអាព្រិច
- អេសាយ ជំពូកទី ៥៩ ៖ ៣

### ខ) បណ្តាសា នាំអោយអាយុជីវិតខ្លី

ប្រទេស **ហ្ស៊ីមបាវ៉េ, ម៉ាឡាវី** និង **ម៉ូហ្សំប៊ិច** អាយុជាមធ្យមរបស់មនុស្សស្លាប់គឺក្រោម ៣៧ ឆ្នាំ។

- 📖 ទំនុកតម្កើង ៣៤ ៖ ១២
- 📖 ១ ថេស្សាឡូនិក ៤ ៖ ៣
- 📖 រ៉ូម ៦ ៖ ២៣

*គ) បណ្ដាសា លើដីចម្ការ (ទិន្នផលតិចតួចបំផុត)*

*នៅក្នុងព្រះគម្ពី **ហាកាយ** បានចែងថាព្រះជាម្ចាស់គឺជាអ្នកបង្អូរទឹកភ្លៀង ហើយទ្រង់ក៏ជាអ្នកធ្វើអោយរុក្ខជាតិដុះចេញពីក្នុងដីមកផងដែរ។*

***<u>ដំណោះស្រាយ៖</u> ការស្ដារឡើងវិញនូវព្រះដំណាក់របស់ព្រះជាម្ចាស់***

*នៅពេលដែលយើងស្វែងរកដំណោះស្រាយ តាមរបៀបរបស់ព្រះជាម្ចាស់ដើម្បីដោះស្រាយបញ្ហាដ៏លំបាក ដូចជាភាពក្រីក្រនៅជុំវិញយើង ជាដំបូងយើងត្រូវចេះគិតពិចារណាពីរបៀបរបស់ដែលខ្លួនប្រព្រឹត្ត ដោយសារយើងគឺជាព្រះដំណាក់របស់ព្រះជាម្ចាស់ដែលមានព្រះជន្មគង់នៅ។*

*ប្រហែលជាយើងមិនអាចផ្លាស់ប្ដូរជាតិសាសន៍របស់យើងភ្លាមៗបានមែន តែយើងម្នាក់ៗអាចគិតពីរបៀបរបស់យើង និង ផ្លាស់ប្ដូរជីវិតរបស់យើងមុនគេ ដើម្បីអោយយើងអាចមានឥទ្ធិពលលើជីវិតរបស់ក្រុមគ្រួសាររបស់យើង និង សហគមន៍ដែលនេះអាចនាំអោយមានការបំផ្លាស់បំប្រែមួយយ៉ាងធំ។*

- 📖 ១ ពេត្រុស ២ ៖ ៥
- 📖 ហាកាយ ២ ៖ ១៨ ~ ១៩
- 📖 ១ ថេស្សាឡូនិក ២ ៖ ១២
- 📖 ២ កូរិនថូស ៦ ៖ ១៦

*តោះយើងដែលជាបុត្រធីតា របស់ព្រះជាម្ចាស់នាំគ្នាប្ដេជ្ញាចិត្ត សាងសង់ព្រះដំណាក់របស់ព្រះអង្គ នៅក្នុងជីវិតរបស់យើងឡើងវិញ ដោយយើងត្រូវគិតពិចារណាឡើងវិញពីរបៀបរស់នៅ ហើយតម្រង់ផ្លូវអោយស្របតាមមាគ៌ារបស់ទ្រង់ មិនមែនតែខាងវិញ្ញាណប៉ុណ្ណោះទេ តែតាមរយៈចិត្តគំនិត និងរូបកាយផងដែរ។*

## គន្លឹះទី ៣ ការស្វែងយល់ពីភាពបរិបូរណ៍របស់ព្រះជាម្ចាស់

<u>**បញ្ហា៖**</u> នៅទ្វីបអាព្រិច ការពឹងតែលើអ្នកដទៃ គឺជាជម្ងឺមួយដែលមាន តាំងពីយូរយាណាស់មកហើយ។ ប្រជាជននៅតែលាដៃសុំពីអ្នកដទៃ តែងតែរំពឹងជំនួយ ពីខាងក្រៅ។ តម្រូវការកាន់តែកើនច្រើនឡើងៗ។ ពិបាកណាស់សម្រាប់ជាតិសាសន៍នៃទ្វីបអាព្រិច ដើម្បីអោយពួកគេអាចទទួលស្គាល់នូវសក្តានុពលរបស់ខ្លួន លុះត្រាតែប្រជាជនចាប់ផ្តើមធ្វើអ្វីមួយ។

**អេសាយ** ជំពូក **៥៨** បានរំលឹកយើងថា យើងគួរតែតមអាហារដោយចិត្តស្មោះសរ យើងគួរស្រាយចំណង និង បម្បែកនឹមរបស់មារចេញ។ ច្រវ៉ាក់មួយនៃនឹមរបស់មារនោះគឺជាជម្ងឺនៃការពឹងតែលើអ្នកដទៃ។

តាំងពីកំណើតផែនដីនេះ មនុស្សបានព្យាយាម បំពេញអ្វីៗទាំងអស់ដោយខ្លួនពួកគេ។ គេធ្វើអ្វីៗ ដោយប្រើប្រាជ្ញាដោយខ្លួនឯង ជាជាងពឹងលើប្រាជ្ញារបស់ព្រះជាម្ចាស់។ ម្លោះហើយបានជានាំអោយ មនុស្សបានធ្លាក់ចុះគ្រប់ផ្នែកនៃជីវិត របស់ពួកគេ។

<u>**ដំណោះស្រាយ៖**</u> **ការស្គាល់ពីភាពបរិបូរណ៍របស់ព្រះជាម្ចាស់**

នៅក្នុង **កសិកម្មតាមរបៀបព្រះជាម្ចាស់** គឺយើងមិនលើកទឹកចិត្តអោយរស់តាមភាពគ្រប់គ្រាន់ល្មមរបស់យើងនោះទេ តែយើងត្រូវចេះទទួលយកភាពបរិបូរណ៍របស់ព្រះជាម្ចាស់ ដើម្បីនាំយើងអោយទទួលផលចំណេញបាន។ ត្បិតទ្រង់ជាព្រះដែលមានធនធាន និងអ្វីៗទាំងអស់ដែលយើងត្រូវការ ហើយនៅក្នុងព្រះអង្គគឺយើងអាចបង្កើនផលទ្វេរដងបាន។ ភាពបរិបូរណ៍របស់ព្រះគឺមិនចេះសាបសូន្យឡើយ គ្មានដែនកំណត់ ត្បិតទ្រង់គឺជាព្រះដែលស្ថិតស្ថេរអស់កល្បជានិច្ច។

២ កូរិនថូស ៩៖៨

ការបម្បែកបណ្តាសានេះបាន គឺនៅពេលយើងសារភាពថាយើងឈប់ពឹងផ្អែកតែលើមនុស្ស និងពឹងតែលើសមត្ថភាពខ្លួនឯង យើងទម្លាក់ចុះភាពអំនួតរបស់យើង

យើងបន្ទាបខ្លួន ហើយចាប់ផ្តើមទទួលស្គាល់ថា ព្រះជាម្ចាស់ទ្រង់ជាប្រភពនៃអ្វីៗទាំងអស់ដែលយើងត្រូវការ។ យើងត្រូវតែរៀនមើលអ្វីដែលទ្រង់ប្រទានអោយមកយើង និងអ្វីៗដែល មាននៅជុំវិញយើង។

**ការស្គាល់ភាពបរិបូរណ៍របស់ព្រះជាម្ចាស់ គឺជាដំណោះស្រាយដើម្បីបំផ្លាញនូវជម្មឺដែលពឹងតែលើអ្នកដទៃ** សូមអាន

២ របាក្សត្រ ១៤ ៖ ១១

**ភាពបរិបូរណ៍របស់ព្រះដែលមាននៅក្នុងយើង** សូមអាន

ទុតិយកថា ៨ ៖ ១៨

**ភាពបរិបូរណ៍របស់ព្រះ ក្នុងការធ្វើកសិកម្ម** សូមអាន

លោកុប្បត្តិ ២ ៖ ១៥

**ភាពបរិបូរណ៍របស់ព្រះ ដែលមានក្នុងដីចម្ការ**

ព្រះបានប្រទានអោយយើងមានដីចម្ការ សម្រាប់កាន់កាប់ ថែរក្សា ហើយនិងដាំដុះ។ វាមិនមែនជាកម្មសិទ្ធរបស់យើងទេ តែជារបស់ព្រះ។ សូមអាន

- 📖 ១ កូរិនថូស ១០ ៖ ២៦
- 📖 លេវីវិន័យ ២៥ ៖ ២៣

**ភាពបរិបូរណ៍របស់ព្រះ ដែលមានក្នុងគ្រាប់ពូជ**

ពេលព្រះអង្គបានបង្កើតដំណាំក្នុងចម្ការមក ទ្រង់បានរៀបចំអោយគ្រាប់ពូជអោយបង្កើតគ្រាប់ពូជ ឡើងតាមប្រភេទនៃគ្រាប់នោះ។

គ្រាប់ពូជបង្កាត់(Hybrid) និង ពូជដើម(Open Pollinated Variety, OPV)

កំណើតពិភពលោក ១ ៖ ១១ ~ ១៣

### *ភាពបរិបូរណ៍របស់ព្រះ ដែលមាននៅក្នុងកម្មចកម្មីស្លឹកឈើងាប់ៗ*

*កម្មចកម្មីស្លឹកឈើងាប់ដែលព្រះបានរៀបចំឡើង គឺមានគោលបំណងផ្តល់អោយដំណាំមានផលផ្លែជាច្រើន យ៉ាងអស្ចារ្យក្រៃលែង។ -សូមអានពត៌មានលម្អិតនៅក្នុង* <u>*មូលហេតុទាំង ២០ យ៉ាងនៃការអនុវត្តន៍កសិកម្មតាមរបៀបរបស់ព្រះជាម្ចាស់*</u>

### *ភាពបរិបូរណ៍របស់ព្រះ ជាមួយការថែទាំលើដីចម្ការ*

*(ជីលាមកសត្វ, ជីដំបូក, ជីកំប៉ុស្តិ៍)*

*ដើម្បីអោយយើងអាចទទួលបានផលល្អ យើងក៏ត្រូវតែតាំងចិត្តក្នុងការដាក់បញ្ចូលនូវជីវជាតិដែលល្អៗ ហើយងាយនឹងរកបានដោយខ្លួនឯងផងដែរ។*

### *ភាពពេញបរិបូរណ៍ ជាមួយនឹងសម្ភារប្រើប្រាស់*

*និក្ខមនំ ៤ ៖២ ព្រះជាម្ចាស់បានសួរលោក* ***ម៉ូសេ*** *ថា "តើនៅក្នុងដៃរបស់អ្នក នោះគឺជាអ្វី? ហើយលោក* ***ម៉ូសេ*** *បានឆ្លើយថា ទូលបង្គំមាន "ដំបងមួយ " ។*

*យើងក៏ត្រូវតែសួរខ្លួនឯងដែរ ថាតើយើងកំពុងតែមានអ្វីនៅក្នុងដៃរបស់យើង ដើម្បីបម្បែកបណ្តាសានៃភាពក្រីក្រ ហើយដើម្បីដោះស្រាយវិបត្តិខ្វះស្បៀងអាហារនៅក្នុងប្រទេសរបស់យើង។* <u>***ចម្លើយគឺ***</u> ***"ចបមួយ "***

### *ភាពពេញបរិបូរណ៍របស់ព្រះ ជាមួយទឹកភ្លៀង និងការទ្វេគុណនៃទិន្នផល*

*ព្រះជាម្ចាស់បានប្រទានពរដល់បុត្រធីតារបស់ព្រះអង្គ តាមរយៈការផ្តល់ទឹកភ្លៀង ហើយជាមួយទឹកភ្លៀងនេះ គឺទ្រង់បានធ្វើអោយគ្រាប់ពូជ បានដុះបង្កើតបានផលឡើងជាហូរហែរ នៅក្នុងក្នុងដីចម្ការរបស់យើង។*

## គន្លឹះទី ៤ អ្នកច្រូតផលនូវអ្វីដែលអ្នកសាបព្រោះ

**បញ្ហា៖** មានសហគមន៍ជាច្រើនដែលកំពុងរស់នៅក្នុងភាពលំបាក ហើយជាកន្លែងដែលគ្មានការអភិវឌ្ឍទាល់តែសោះ។ ពួកគេរស់នៅដោយភាពខ្វះខាត ដោយសារតែធនធានក្នុងតំបន់របស់ពួកគេមានកំណត់។ អាហាររបស់គេមិននៅសល់ឡើយ។ គេចាប់ផ្តើមសម្របខ្លួននិងការរស់នៅបែបនេះ ហើយគេគិតថា ម្ចាស់ជំនួយ និងជួយគេថែមទៀតនៅពេលដែលគេខ្វះខាត។ ប្រសិនជាយើងនៅតែបន្ត ពឹងផ្អែកតែលើមនុស្សសម្រាប់ការផ្គត់ផ្គង់ ជាជាងពឹងផ្អែកលើព្រះជាម្ចាស់ វាគឺជាការពឹងទៅលើប្រភពដែលខុសឆ្គងហើយ។

២ ថេស្សាឡូនិក ៣ ៖ ១០ "***អ្នកណាមិនព្រមធ្វើការ អ្នកនោះក៏មិនត្រូវបរិភោគដែរ***"

ការងារគឺមិនមែនជាបណ្តាសានោះទេ តែជាព្រះពរដែលមកពីព្រះជាម្ចាស់វិញ។ តាមពិតទៅប្រជាជនក្រីក្រដែលរស់នៅតំបន់នោះ គឺមានដីចម្ការ ប៉ុន្តែពួកគេបានទុកវាចោល។

ប្រទេសអាព្រិចត្រូវបានគេស្គាល់ថាជាប្រទេសក្រីក្រកាន់ចានសុំទាន តែប្រែទៅជាកាន់កន្ត្រកដែលពោរពេញទៅដោយអាហារទៅវិញ។

របៀបរបស់ព្រះជាម្ចាស់ គឺចង់អោយមនុស្សរីកចម្រើនឡើងតាមគោលការណ៍របស់ព្រះអង្គ។ ហើយនេះគឺជារបៀបមួយដែលទ្រង់អាចប្រទានរង្វាន់ ដោយផ្អែកលើគោលការណ៍នៃការសាបព្រោះ និងគោលការណ៍នៃការច្រូតកាត់។ វាគឺជាទំនួលខុសត្រូវក្នុងការរ៉ាប់រង និងភាពស្មោះត្រង់ចំពោះអ្វីដែលព្រះបានប្រទានអោយអ្នក។

**ដំណោះស្រាយ ៖ យើងត្រូវតែចេះឲ្យ ដើម្បីទទួលបានផល**

នៅពេលដែលយើងដឹងថា ព្រះជាម្ចាស់គឺជាប្រភពរបស់យើង ហើយទ្រង់គឺមានអ្វីៗទាំងអស់ដែលយើងត្រូវការ នោះទើបយើងអាចចាប់ផ្តើមលះបង់ចរិកចាស់របស់យើង ហើយយើងលែងរស់ដោយគ្រាន់តែ ពឹងពាក់លើអ្នកដទៃ តែយើងអាចទុកចិត្តលើព្រះវិញ។

កិច្ចការ ២០ ៖ ៣៥ "**ការឲ្យគឺប្រសើរជាងការទទួល**"

ការផ្លាស់ប្តូរផ្នត់គំនិតពីការសុំ មកជាការអោយគឺវាមានឥទ្ធិល។ វាអាចជួយអោយមានការឈោងចាប់ដល់ជាតិសាសន៍ដទៃ ជាមួយនិងដំណឹងល្អ របស់ព្រះយ៉េស៊ូ។

លូកា ៦ ៖ ៣៨

សុភាសិត ២៨ ៖ ១៩ ការច្រូតកាត់ តាមព្រះគម្ពីរ។ យើងត្រូវតែសាបព្រោះ ដាក់ជី និងសារធាតុដទៃទៀតអោយដី ។ ការប្រើកំលាំងរបស់យើង ការចំណាយពេលវេលា ការគ្រប់គ្រង និងដើមទុនយើងខ្លះៗដើម្បីអោយយើងអាចទទួលបានផលមកវិញ។ យើងមិនអាចចាំតែទទួលតែមិនសាបព្រោះនោះទេ។ ព្រះគម្ពីបានចែងថា យើង សាបព្រោះអ្វីនោះយើងនឹងច្រូតផលនោះ។ **សូន្យ** គុណនិង **សូន្យ** គឺស្មើរនិង **សូន្យ** រឺ **សូន្យ** គុណនិង ១០០ គឺនៅតែស្មើរ **សូន្យ** ដដែល។ វាមានន័យថា បើយើងអត់សាប ព្រោះសោះ ទៅលើដីដែលមានទំហំរាបហិចតា នោះយើងក៏មិនបានទទួលផលអ្វីលើដីដែលយើងមាននោះដែរ។ ហើយបើយើងអត់សាបព្រោះអ្វីសោះនៅលើដីដែលមានគុណភាពល្អ ក៏យើងមិនទទួលផលអ្វីទាំងអស់។

**របៀបដែលយើងអាច សាបព្រោះបាន**

*ត្រូវសាបព្រោះអោយបានច្រើន*

នៅក្នុង ២ កូរិនថូស ៩ ៖ ៦ បានចែងថា "អ្នកណាព្រោះតិច អ្នកនោះក៏ច្រូតបានតិចដែរ រីឯអ្នកដែលព្រោះច្រើនបរិបូណ៌ ក៏ច្រូតបានផលច្រើនបរិបូរណ៌ដែរ"

*សាបព្រោះដោយប្រើចំណេះដឹង*

*ភាគច្រើននៅតំបន់អាព្រិច បញ្ហាភាពក្រីក្ររបស់កសិករ មិនមែនដោយសារតែភាពខ្ជិល ឬការទុកឲ្យដីនៅទំនេរនោះទេ គឺមកពីមនុស្សខ្វះចំណេះដឹង។*

*ហូសេរ ៤ ៖ ៦ "ប្រជាជនរបស់យើងវិនាស ដោយសារពួកគេខ្វះចំណេះដឹង"*

*សាបព្រោះដោយភាពស្មោះត្រង់*

*អាថ៌កំបាំងនៃការធ្វើ **កសិកម្មតាមរបៀបព្រះជាម្ចាស់** គឺចាប់ផ្តើមពីអ្វីដែលតូច ហើយត្រូវស្មោះត្រង់និងអ្វីដែលតូចនោះ។ **លូកា ១៦ ៖ ១០ " អ្នកស្មោះត្រង់ និង កិច្ចការតូច ក៏ស្មោះត្រង់និងកិច្ចការដ៏ធំដែរ"***

*សាបព្រោះដោយភាពអំណរ*

*ឥរិយាបទដែលយើងមានគឺមានសារៈសំខាន់ណាស់*

*២ កូរិនថូស ៩ ៖ ៧*

*នេហេមា ៨ ៖ ១០*

*អំណររបស់យើងគឺមានក្នុងព្រះអង្គម្ចាស់ក៏ប៉ុន្តែយើងត្រូវឲ្យជីវិតរបស់យើងរស់ក្នុងភាពអំណរ គឺអំណរសូម្បីតែការក្នុងដៃរបស់យើងក៏ដោយ។*

## គន្លឹះទី ៥ ការនាំផង្វាយ និង ផង្វាយមួយភាគដប់មកកាន់ព្រះជាម្ចាស់

*ចូរពិចារណា ពីលក្ខណៈរបស់ព្រះជាម្ចាស់ ពីអំណាចនិងធនធានដែលព្រះជាម្ចាស់មាន។ តើយើងអាចលួចព្រះជាម្ចាស់បានយ៉ាងដូចម្តេច? បើយោងតាម ខគម្ពី **ម៉ាឡាគី** ជំពូក៣ គឺអាចលួចពីព្រះជាម្ចាស់បានតាមរយៈ ការដែលយើងមិនដាក់ដង្វាយមួយ*

ភាគដប់ និងដង្វាយផ្សេងៗ។ នៅសម័យនោះ គឺជាសង្គមដែលប្រជាជន ធ្វើស្រែចម្ការ ហើយចិត្តនៃការឲ្យរបស់គេគឺមានឥទ្ធិពលដល់ការធ្វើដីចម្ការរបស់ពួកគេ។

ម៉ាឡាគី ៣ ៖ ៧-១២

ការដាក់ដង្វាយមួយភាគដប់ មកកាន់ក្រុមជំនុំគឺ ជាការឲ្យមកកាន់ព្រះជាម្ចាស់។ ព្រះជាម្ចាស់ទ្រង់មិនខ្វល់ពីចំនួនទ្រព្យធនរបស់យើងនោះទេ តែការថ្វាយវាគឺបង្ហាញទ្រង់នូវចិត្តរបស់យើង ថាពិតជាទទួលស្គាល់ទ្រង់ថា សំខាន់ក្នុងការឲ្យរបស់យើងមែន។

ម៉ាថាយ ៦ ៖ ២១

ការឲ្យរបស់យើងដល់ស្ត្រីមេម៉ាយមិនថាតិចតួច ឬរាប់រយលានដុល្លារក្នុងមួយខែនោះទេ គឺមិនមានអ្វីភ្ញាក់ផ្អើលដល់ព្រះជាម្ចាស់នោះទេ។ ព្រះជាម្ចាស់បានជ្រាបពីអ្វីដែលយើងមាន តាមពិតអ្នកក្រនិងស្ត្រីមេម៉ាយគឺមានតម្លៃជាជាងប្រាក់រាប់លានដុល្លារដែលយើងថ្វាយមកក្នុងដំណាក់ទ្រង់ទៅទៀត។ ព្រះជាម្ចាស់ទ្រង់ដឹងពីចិត្តរបស់យើងមុនយើងថ្វាយដង្វាយទៅទៀត។ ទ្រង់វាល់តាមដួងចិត្តរបស់យើងក្នុងការឲ្យ។ ទ្រង់វាល់តាមដួងចិត្តរបស់យើងមិនមែនលុយរបស់យើនោះទេ។

អ្វីដែលសំខាន់ក្នុងការថ្វាយទៅកាន់ព្រះជាម្ចាស់ គឺសំរាប់ប្រយោជន៍របស់យើង រាល់គ្នាប៉ុណ្ណោះ។ ព្រះជាម្ចាស់មិនបានរៀបចំដង្វាយដែលយើងថ្វាយ សំរាប់ជាប្រយោជន៍ក្នុងឃ្លាំង ដំណាក់របស់ទ្រង់នោះទេ។ ប៉ុន្តែគឺសំរាប់ព្រះពរដល់អ្នកណាដែលចេះអោយ។ ព្រះពរនិង កើតមានដល់អ្នកអោយទ្វេដង។

១) ព្រះជាម្ចាស់បានសន្យាថា ទ្រង់និង បើក ទ្វានៃឋានសួគ៌ ហើយចាប់បង្ហូរព្រះពរដ៏លើសលប់។ សុភាសិត ៣៖ ៩

២) ព្រះជាម្ចាស់ ទ្រង់និងកំទិចរាល់សត្វចង្រៃដែល ព្យាយាមបំផ្លាញដំណាំ និងដីចម្ការរបស់អ្នក។

៣) ព្រះជាម្ចាស់ និង ធ្វើអោយជាតិសាន៍ដ៏ទៃ ហៅអ្នកថាជា អ្នកទទួលព្រះពរដោយសារតែអ្នកជា អ្នកសំណប់របស់ព្រះជាម្ចាស់។

ការថ្វាយទៅព្រះជាម្ចាស់ គឺជាការផ្តល់កិត្តិយស និង ជាការទទួលស្គាល់ទ្រង់ តាមរបៀបមួយដែលយើងមិនអាចយល់បាន។ ការថ្វាយទៅព្រះជាម្ចាស់ គឺ នាំអោយយើងពិចារណាលើហេតុផលនៅខាងក្រៅខ្លួនយើង ហើយយើងអាចចាប់ផ្តើម ដំណើរជីវិតមួយដែលយើង ដាក់ព្រះរាជរបស់ព្រះជាម្ចាស់ ជាជាងភាព អាត្មានិយមរបស់យើង។

## គន្លឹះទី ៦ ទាមទារអ្វីដែលជារបស់អ្នក

យើងគួរតែដាក់ព្រះជាម្ចាស់ក្នុងគ្រប់ផ្នែកទាំងអស់នៃជីវិតយើងជាពិសេសគឺអនុញ្ញាតអោយយើងចូលរួមចំណែកក្នុងកិច្ចការ កសិកម្មរបស់យើង។ យើងត្រូវតែប្រកាសទាមទារយកមកវិញ នូវដីដែលធ្លាប់ស្ថិតនៅក្រោមបណ្តាសាដែលបណ្តាល មកពីការថ្វាយបង្គំព្រះក្លែងក្លាយ អំពើធ្មប់ ការបង្ហូរឈាមជនស្លូតត្រង់ និងទង្វើអាក្រក់ផ្សេងៗទៀតហើយយើងត្រូវតែទទួលស្គាល់នូវកិច្ចការទាំងនេះនៅចំពោះមុខ**ព្រះជាម្ចាស់**។

**យ៉ាកុប ៥៖១៤** "ពាក្យអធិដ្ឋានរបស់មនុស្សសុចរិតគឺមានប្រសិទ្ធភាពណាស់"

**សុភាសិត ១៥៖២៩** "ព្រះជាម្ចាស់មិនអើពើនិងមនុស្សអាក្រក់ទេតែព្រះអង្គស្តាប់ពាក្យទូលអង្វររបស់មនុស្សសុចរិត"

**២ របាក្សត្រ ៧៖១៤** "ប្រសិនបើប្រជារាស្ត្ររបស់យើងគឺជាប្រជារាស្ត្រដែលជាកម្មសិទ្ធិរបស់យើងផ្ទាល់នាំគ្នាបន្ទាបខ្លួនអធិដ្ឋាននិងស្វែងរកយើងហើយប្រសិនជាគេបោះបង់ចោលផ្លូវអាក្រក់របស់ខ្លួនយើងនិងស្តាប់គេពីស្ថានបរមសុខយើងនិងប្រោសស្រុកគេឲ្យបានជាផង"

នៅពេលដែលមនុស្សចាប់ផ្តើមទទួលភាពសុចរិតរបស់ព្រះជាម្ចាស់ តាមរយៈព្រះយេស៊ូគ្រីស្ទ គេគួរតែចេះអធិស្ឋានទាំងមានសេចក្តីជំនឿទៅលើទ្រង់ គ្រប់ទាំងព្រះបន្ទូលនិងសេចក្តីសន្យារបស់ទ្រង់ដែរ ហើយនិងផ្តល់អោយគ្រប់ទាំងស្រែចម្ការ ព្រមទាំងសហគមន៍បានចម្រុងចម្រើនឡើង។

*យើងត្រូវប្រកាសទាមទារអ្វីដែលជារបស់យើង ក្នុងនាមជាបុត្រធីតារបស់ព្រះជាម្ចាស់ ហើយយើងមានព្រះជន្មរបស់ព្រះបុត្រាគង់ក្នុងជីវិតរបស់យើង ក្នុងគ្រប់ផ្នែកទាំងអស់នៃជីវិតរបស់យើង។ ព្រះយេស៊ូបានបង្រៀនយើងឲ្យចេះអធិដ្ឋាន "សូមឲ្យព្រះរាជរបស់ទ្រង់ មកដល់ផែនដីនេះដូចនៅស្ថានសួគ៌ដែរ"*

## ***របៀបប្រកាសទាមទារអ្វីដែលជារបស់អ្នក***

- *ការបន្ទាបខ្លួនគឺជាចំណុចចាប់ផ្តើម (យ៉ាកុប ៤ ៖ ១០)*
- *ត្រូវស្វែងរកព្រះភ័ក្ត្ររបស់ព្រះ មិនមែនគ្រាន់តែស្វែងរកតែអ្វីដែលទ្រង់ធ្វើនោះទេ។ (ទុតិយកថា ៤ ៖ ២៩)*
- *ត្រូវសារភាពអំពើបាប និងការកែប្រែចិត្តគំនិត*
- *ត្រូវទូលសុំ នោះអ្នកនឹងទទួល (**ម៉ាថាយ ៧ ៖ ៧** និង **យ៉ាកុប ៤ ៖ ២**)*
- *ត្រូវអធិដ្ឋាន*
- *ត្រូវឈរអោយរឹងមាំ (**អេភេសូ ៦ ៖ ១០** និង **រ៉ូម ៨ ៖ ៣**)*

*ព្រះជាម្ចាស់គឺនៅខាងយើង ហើយទ្រង់គឺមិនប្រឆាំងនិងយើងឡើយ។ ទ្រង់សព្វព្រះហឫទ័យប្រទានពរដល់ដីចម្ការរបស់យើង។ យើងត្រូវយកមកវិញនូវទឹកដីរបស់យើងដែលសត្រូវបានកាន់កាប់។*

# **ដំណាក់កាលតាមលំដាប់លំដោយ**

នៅក្នុងផ្នែកនេះគឺជាការរៀបរាប់ អំពីដំណើរការ តាមជំហានដែលអ្នកគួរតែធ្វើតាមដើម្បីឲ្យបច្ចេកទេស **កសិកម្មតាមរបៀបព្រះជាម្ចាស់** អាចទទួលបានជោគជ័យនៅលើដីចម្ការរបស់អ្នក។

## ១) សម្ភារៈដែលត្រូវការ

- ខ្សែកាប

  នេះគឺជាឧបករណ៍សម្រាប់វាស់វែង ដើម្បីធានាថាវាពិតជាត្រឹមត្រូវទៅតាមខ្នាតគំរូជាក់លាក់នៃដង់ស៊ីតេចំនួនប្រជាករដំណាំ។ ចូរជ្រើសរើសខ្សែដែលវែង (អាចមានប្រវែងលើសពី ៥០ ម៉ែត្រ) មិនយឺត ហើយជាខ្សែរឹងមាំដែលធ្វើពីនីឡុង ខ្សែកាបស្កត់បិត ពីដើមកក់ និយាយជារួមទៅជាប្រភេទខ្សែដែលរឹងមាំដែលពេលកាប់ត្រូវមិនងាយដាច់។ ចូរកាត់ឈើប្រវែង ៦០ស.មមួយ ដើម្បីងាយវាស់នៅលើខ្សែកាបដែលយើងយកមកនោះ។ ត្រូវទាញខ្សែឲ្យតឹងសិន ចាំគៀបគំរបចំណាំ ពីម្ខាងទៀតទៅម្ខាងទៀត អាចយកគំរបដប ឬជាខ្សែពណ៌ចងចំណាំពីលើក៏បាន។ ចូរចាំថាចន្លោះពីម្ខាងទៅទៀតគឺ ៦០ សង់ទីម៉ែត្រ (៦តឹក)។
- ចបកាប់
- ប្រអប់ឈើគូស
- ឈើសម្រាប់វាស់មានពីរ ៦០ សង់ទីម៉ែត្រ (**៦តឹក**) និង ៧៥ សង់ទីម៉ែត្រ (**៧.៥តឹក**)
- ជីលាមកសត្វ ជីកំប៉ុស្តិ៍ ដីដំបូក ឬ ជីអសរីរាង្គ
- គ្រាប់ពូជ
- កូនស្លាបព្រា
- ស្លាបព្រាបាយ
- ពែង ឬក៏កំប៉ុងចំណុះ ៣៥០ មីលីលីត្រ (ជិតកន្លះលីត្រ)

## ២) ការរៀបចំដី

- ចាប់ផ្ដើមរៀបចំប្រហែលជា២ខែ មុនរដូវដាំដុះចូលមកដល់
- ចាប់ផ្ដើមអ្វីដែលតូច ហើយត្រូវធ្វើឲ្យល្អ តាមស្ដង់ដារខ្ពស់។ ចូរស្វែងរករបស់របរណាដែលងាយរកនៅតំបន់របស់អ្នក។
- ចូរកុំភ្ជួរអោយសោះ
- ចូរកុំដុត កំទេចកំទីស្លឹកឈើងាប់ៗនៅលើដី
- ប្រសិនជាដីថ្មីត្រូវ គាស់គល់ឈើដែលនៅសល់ ៣ម្រាបដីឲ្យស្មើនិងជំរះស្មៅឲ្យស្អាត។
- ប្រសិនជាដីពោរពេញទៅដោយស្មៅចង្រៃ ចូរគ្រាន់តែប្រើចបកាប់ឆាយវាចូលទៅក្នុងដី ៣ម្រាបវាឲ្យស្មើ ហើយទុកវាឡប់លែជាមួយស្លឹកឈើងាប់ដែលមាននៅលើដីស្រាប់។

## ៣) ការបង្កើតខ្សែបន្ទាត់និរន្តភាព

- ចាប់ផ្ដើនៅផ្នែកខាងលើនៃដី (ត្រូវដឹងពីទិសដៅទឹកហូរ)
- វាយខ្សែកាប (ប្រវែង ៦០សង់ទីម៉ែត្រ) តាមកែងកាច់ជ្រុងរបស់ដី
- ត្រូវដាក់វាឲ្យចំចំណុច ៩០ ដឺក្រេ តាមជ្រុងរបស់ដី
- ដោតឈើទាំងពីរ នៅខាងលើក្បាលដី
- វាស់ឲ្យមានរាងចតុកោណកែងដោយប្រើ ក្រដាសជ្រុង (A4) ឲ្យចំកែងហើយទាញខ្សែឲ្យវាត្រង់។

៤) ការជីកងីដាក់គ្រាប់ពោត

- គំលាត៖ ៦០ស.ម( ៦តឹក ) ចន្លោះគុម្ពនិមួយៗ (ប្រែប្រួលទៅតាមដំណាំ)។
- ទទឹងនៃរណ្តៅ៖ ស្មើនឹងមួយចប ( ១២សង់ទីម៉ែត្រ )
- ជម្រៅ៖ ១៥ស.ម នៅពេលដែលប្រើល្បាយសរីរាង្គ។ ឧទា. ជីលាមកសត្វ ជីកំប៉ុស្តិ៍ និង ជីសំបុកកណ្តៀរ។
- ជម្រៅ៖ ៨ សង់ទីម៉ែត នៅពេលដែលប្រើជីអសរីរាង្គ។ ឧទា. ជី DAPជាដើម។
- ទុកឲ្យមានពំនូកដី និងជម្រាល។



- ចូររើខ្សែកាប ( ៦តឹក ) ចុះទៅជួបបន្ទាប់ ដោយប្រើកូនឈើ ( ៣.៥តឹក) ដើម្បីវាស់ឲ្យមានគម្លាតស្មើគ្នាដោយត្រឹមត្រូវ(ចន្លោះរងដំណាំ)។
- ចូរជីករណ្តៅទី២ ទៅតាមអ្វីដែលបានបង្ហាញជូននៅខាងលើ ដោយបន្តដាក់គម្លាតវាអោយស្មើៗគ្នាគឺ ៣៥ស.ម (៣.៥តឹក) មុនចាប់ផ្តើមធ្វើជួរមួយទៀត។
- នៅលើទំហំដី ដោតកូនឈើចន្លោះពី ១០ ទៅ ២០ ជួរ ដើម្បីដាក់ជួរឲ្យត្រង់។

## ជំរើសដាំគ្រាប់ពូជទៃផ្សេងទៀតៗ

- ចន្លោះនៅតាមជួរនិមួយៗ គឺវាមានលក្ខណៈតូចល្មមសម្រាប់ដាក់គ្រាប់ផ្សេងៗ ដូច្នេះយើងមិនអាចប្រើរន្ធនេះបានទេ តែយើងអាចដាំនៅលើរងបន្តតាមជួរៗរបស់វា។
- ដោតខ្សែរកាប តាមជួរនិមួយៗ ត្រូវការជម្រៅ ៨ស.ម បន្ទាប់ពីរងទាំងនោះ
- សូមមើលតារាងក្នុងផ្នែកដំណាំជំនួសសម្រាប់ព័តិមានលម្អិតបន្ថែម។



៥) *ការដាក់កំបោរ (បន្សាបដីដែលមានជាតិអាស៊ីត)*

- *ជាញឹកញាប់ដីដែលមានពណ៌ក្រហម នៅក្នុងតំបន់ដែលមានភ្លៀងធ្លាក់ច្រើនគឺមានផ្ទុកទៅដោយជាតិអាស៊ីត ហើយវាក៏ធ្វើអោយរាំងស្ទះនូវសារធាតុដែលចាំបាច់សម្រាប់រុក្ខជាតិដុះលូតលាស់ផងដែរ។*
- *កំបោរកសិកម្មគឺជួយបង្កើន PH ដី ដែលបណ្តាលអោយសារធាតុចិញ្ចឹម កាន់តែងាយស្រួលសម្រាប់អោយឫសរុក្ខជាតិអាចស្រូបយកបាន។*
- *ចូរដាក់កំបោរមួយស្លាបព្រាកាហ្វេ (៥ml) ចូរក្នុងរន្ធនិមួយៗនៅតាមបាតរន្ធនោះប្រសិនជាអ្នកមិនទាន់បានធ្វើការវិភាគដីនៅឡើយ។ តែប្រសិនជាអ្នកបានធ្វើការវិភាគដីរួចរាល់ហើយ អ្នកត្រូវតែប្រើប្រាស់កំបោរតាមការណែនាំនោះ។*
- *ប្រសិនជាគ្មានកំបោរអ្នកអាចប្រើផេះមួយស្លាបព្រាបបាយ ឬ ក៏លាយផេះចំនួនមួយទៅពីរថង់ ច្របល់ចូលទៅក្នុងពំនូកដីកំប៉ុស្តិ៍ក៏បានដែរ។*

៦) *ការដាក់ជី*

*ជីគឺមាន២ ប្រភេទ៖ ជីសរីរាង្គ និងជីអសរីរាង្គ*

***ជីសរីរាង្គ***

- *ជីកំប៉ុស្តិ៍, ជីលាមកសត្វ, ជីសំបុកកណ្តៀរ ឬជីដំបូក។*
- *ចូរប្រើកំប៉ុង ឬក៏ពែង ដែលមានចំណុះ ៣៥0ml (មីលីលីត្រ)។*
- *ចូរដាក់វាអោយស្មើៗគ្នាពីបាតរណ្តៅមួយទៅបាតរណ្តៅមួយ។*
- *ទិន្នផលដែលអាចទទួលបានក្នុងផ្ទៃដីមួយហិចតាសម្រាប់ដំណាំពោត គឺចន្លោះពី ៣ ទៅ ៥តោន ដោយប្រើជីលាមកសត្វ ហើយពី ១ ទៅ ៣តោនជាមួយជីដំបូក។*
- *ចូរដាក់ជីចំនួន ៣៥0ml(មីលីលីត្រ) តាមរងនិមួយៗឆ្លងពីគុម្ពមួយទៅគុម្ពមួយគឺ ៦0cm (៦តឹក)។*
- *ចំពោះដំណាំដែលត្រូវការសារធាតុចិញ្ចឹមតិចតួច ឧទា. ស្ពៃ/ស្រូវមីយេ, ត្រូវដាក់ជីតាមរង្វាស់ម៉ែត្រអោយបានត្រឹមត្រូវ។*

### ជីអសរីរាង្គ

- ជីនេះចែកចេញជា ២ ប្រភេទគឺ៖ ជីទ្រាប់បាត និង ជីបំប៉ន។
- ប្រភេទនៃជីទ្រាប់បាតមានដូចជា ដេអាប៉េ(DAP) ឬ អិនពីខេ(NPK) ប្រើក្នុងកម្រិតផ្សេងៗគ្នា។
- ចូរប្រើជីទ្រាប់បាតទៅដាក់នៅផ្នែកខាងក្រោមបង្អស់នៃបាតរណ្តៅ។
- ដើម្បីឲ្យទិន្នផលល្អយើងត្រូវដាក់ជី DAP ១២ml(មីលីលីត្រ) ឬក៏មួយស្លាបព្រាបាយនៃជី DAP ក្នុងចន្លោះចង្អូរតូចៗពីបាតរណ្តៅមួយទៅបាតរណ្តៅមួយទៀត។
- ប្រសិនជាអ្នកដាំដំណាំដូចជា សណ្តែក នៅចង្អូរនោះ គឺគ្រាន់តែរាយមួយស្លាបព្រាកាហ្វេពេញ រាល់ ៦0cm (៦តឹក) ម្តងក្នុងចង្អូរនោះបានហើយ។

### ការកំណត់ទូទៅ

- ចូរគៀសដីដាក់ពីលើបន្តិចឲ្យមានកម្រាស់ ៣ស.ម រហូតដល់តម្រូវការគ្រាប់អាចកប់ចូលក្នុងដីហើយការដាំគ្រាប់ពូជជម្រៅដែលនៅសល់គឺ (៥ ស.ម សម្រាប់ដំណាំពោត, ៣ស.មសម្រាប់ដំណាំសណ្តែក)។
- ចូររងចាំទឹកភ្លៀងអោយមានគ្រប់គ្រាន់សិន។

## ៧) ការដាំដុះ

- យើងគួរតែរៀបចំដីអោយហើយ យ៉ាងហោចណាស់ ៣ សប្តាហ៍ មុនរដូវកាលដាំដុះក្នុងតំបន់របស់អ្នកឈានចូលមកដល់។ ឧទា. នៅបណ្តាប្រទេសអាព្រិចខាងត្បូងគេត្រូវរៀបចំដីអោយរួចរាល់មុនខែតុលា។
- យល់ល្អគួរតែប្រើគ្រាប់ពូជប្រភេទ OPV ដោយសារតែគ្រាប់ពូជប្រភេទនេះអាចយកមកដាំឡើងវិញជារៀងរាល់ឆ្នាំ ហើយយើងអាចដាំវាជាច្រើនឆ្នាំបានផងដែរ។
- ចូរដាំ ៣ គ្រាប់/រណ្តៅ ឬ ២ គ្រាប់/រណ្តៅ (៤៤,000 គ្រាប់/ហិចតា)។
- ចូរដាក់គ្រាប់អោយត្រង់ជួរ ឆ្លងពីបាតរណ្តៅមួយទៅមួយទៀត។

- ការដាំគឺជម្រៅ គិតតាមប្រអប់ឈើគូស សម្រាប់ដំណាំពោតរ៉ាស់តាមបណ្តោយប្រអប់, សម្រាប់ដំណាំសណ្តែកសៀងរ៉ាស់តាមទទឹងប្រអប់ឈើគូស, ចំពោះដំណាំស្រូវសាលីយកកម្ពស់ប្រអប់ឈើគូស។
- ប្រសិនជាដាំដំណាំសណ្តែក ចូរដាក់គ្រាប់សណ្តែក ១០ស.ម នៅចន្លោះបណ្តោយចង្អូរ។
- ចូរគ្របដីអោយបានស្អាត ហើយជុំដីអោយមានផ្ទៃស្មើកុំអោយមានខ្ពស់ទាប។ ត្រូវប្រាកដថាគ្មានដុំគ្រួស ដុំដីរឹងៗ ឫភួយដែលប្រើហើយត្រូវបានគ្របពីលើទេ។
- ចូរគ្របផ្ទៃដីចម្ការរបស់អ្នកជាមួយនឹងស្លឹកឈើងាប់ៗ ដែលងាយនឹងពុកផុយ។

**ចូរចងចាំថា៖** សម្រាប់គ្រាប់ដំណាំតូចៗដូចជា៖ ការ៉ុត, Spinach(បន្លែម្យ៉ាងដូចស្ពៃខ្មៅ) និងបន្លែផ្សេងៗទៀត។ យើងត្រូវរក្សារងរបស់បន្លែកុំអោយមានស្លឹកឈើងាប់ រហូតដល់បន្លែចាប់ផ្តើមដុះឡើង។

## ៨) ការគ្រប់គ្រងរុក្ខជាតិចង្រៃ

- រុក្ខជាតិចង្រៃ វាធ្វើអោយទិន្នផលដំណាំធ្លាក់ចុះយ៉ាងខ្លាំង ក៏ព្រោះតែវាមានការប្រកួតប្រជែងជាមួយដំណាំ រួមមានទាំង ទឹក សារធាតុចិញ្ចឹម ពន្លឺ ហើយនិង ទីធ្លាផងដែរ។
- នៅពេលស្មៅចង្រៃនៅតូច សម្រាប់ផ្ទៃដីមួយហិចតា ក្នុងរយៈពេល ៧ថ្ងៃវាមានកម្ពស់ប្រហែល ២.៥ស.មប៉ុណ្ណោះ ប៉ុន្តែក្នុងរយៈពេលត្រឹម ១៤ថ្ងៃ វាមានកម្ពស់រហូតដល់ ៣០ស.ម(សង់ទីម៉ែត្រ)។ ដូចនេះចូលជម្រះវាអោយទាន់ពេលវេលា។
- វដ្តជីវិតរបស់ស្មៅចង្រៃគឺ ១០ ថ្ងៃប៉ុណ្ណោះ។ ដូច្នេះយើងមានពេលច្រើនប្រសិនជាយើងកាត់វានៅកម្ពស់ ២.៥ស.ម។ ប៉ុន្តែប្រសិនជាទុកអោយវាមានកម្ពស់រហូតដល់ ៣០ស.មទើបកាត់វាពិបាក ហើយនិងខាតបង់ច្រើនណាស់។

- ចូរកាត់ស្មៅចង្រៃចេញពីផ្ទៃដី ដោយដើរថយក្រោយព្រោះវាងាយស្រួល។
- ចូរដកវាចេញពីដីស្រែទាប់លើ ចំពោះពពួកស្មៅដែលមានដើមដុះវារ ហើយត្រូវយកវាចេញពីដីដាំដំណាំរបស់អ្នក ឬក៏ប្រើប្រភេទថ្នាំបាញ់ដែលកម្ចាត់ដោយជ្រើសរើស(Selective Herbicide)។
- ចូរកុំអោយគ្រាប់ស្មៅចង្រៃធ្លាក់នៅក្នុងដីដាំដំណាំរបស់អ្នកអោយសោះ។

៩) ការកាត់ឬដកដើមដែលមិនសំខាន់ចោល

- ចូរកាត់ឬដកដើមដែលមិនសំខាន់ចោលនៅចន្លោះពេលពី ២ ទៅ ៣ សប្តាហ៍ បន្ទាប់ពីវាបានដុះចេញពីគ្រាប់ពូជនៅកម្ពស់ប្រមាណជា ២០ ទៅ ៣០ស.ម។
- ចូរកាត់ឬដកវាចេញព្រោះជាមធ្យម ត្រូវទុកតែ២ដើម/មួយរណ្តៅបានហើយ។
- ចូរមើល ៣ រណ្តៅម្តងមិនមែន ១ រណ្តៅម្តងទេ។

**ចូរមើលឧទាហរណ៍ខាងក្រោមនេះ**

ចូរកាត់ឬដកដើមដែលខ្សោយបំផុត និងដើមដែលនៅកណ្តាល ប្រសិនជាមាន ការដុះ ៣ ដើមក្នុងមួយរណ្តៅ



ដកដើមកណ្តាល ដកដើមខ្សោយបំផុត ដកដើមខ្សោយបំផុត

នៅពេលមានដើមតែមួយដុះរវាង រណ្តៅពីរទៀត (ទី១មានបី ទី២មានមួយ និងទី៣ មានតែពីរ) អ្នកមិនត្រូវកាត់វាទេ។



៧ ដើមក្នុងរវាង ៣រណ្តៅ, ដូចនេះដក ១ ដើមចេញពីរណ្តៅដែលមាន ៣



ដកដើមខ្សោយ ឬកណ្តាលចេញ

## ១០) ការដាក់ជីបំប៉ន (ដំណាំពោត)

ដើម្បីអោយទទួលបានទិន្នផលបានខ្ពស់ យើងគួរតែប្រើប្រាស់ជី មួយក្នុងចំណោម ជីបំប៉នទាំង ២ ប្រភេទនេះគឺ៖ អាម៉ូញ៉ូមនីត្រាត(AN) និង អ៊ុយរ៉េ(Urea)។

ការដាក់ជីលើកដំបូងនៅពេលកូនទើបដុះបានពី ២ ទៅ ៣ សប្តាហ៍

- ៨ ម.ល(មីលីលីត្រ) ពេង ឬមួយស្លាបព្រាកាហ្វេពេញ។
- ចូរដាក់ ៧ស.ម ចេញពីដើមនៃរុក្ខជាតិ។

ការដាក់ជីលើទី ២ មុនការដុះពន្លកផ្កា

- ៥ ម.ល ឬ មួយស្លាបព្រាកាហ្វេពេញ។
- ចូរដាក់ ១០ស.ម ចេញពីដើមនៃរុក្ខជាតិ ។

## ១១) ការគ្រប់គ្រងស្មៅចង្រៃមុនរដូវកាលប្រមូលផលមកដល់

- នៅពេលដែលស្លឹកពោតវាចាប់ផ្តើមត្រលប់ទៅជាស្លកពណ៌ វាក៏ចាប់ផ្តើមខ្សោយទៅៗហើយងាប់ជ្រុះ ធ្វើរុក្ខជាតិចង្រៃអាចដុះឡើងវិញសារជាថ្មី។
- ចូរជម្រះស្មៅចង្រៃនៅដំណាក់កាលដំបូងនេះអោយអស់ ជៀសវាងទុកអោយដីនៅទំនេរដុះស្មៅពាសពេញឡើយវិញ។ ការទុកស្មៅអោយដុះនៅពាសពេញដីបែបនេះនៅពេលដែលអ្នកដាំដំណាំវានឹងធ្វើអោយដំណាំបាត់បង់ទិន្នផល។

## ១២) ស្រទាប់លើដី

- នៅពេលដែលផ្លែគ្រប់អាយុ គឺវាចាស់ល្មមហើយ។ ចូរកាច់ឬកាប់ដើមនិងស្លឹករបស់វាយកមកទុកធ្វើជាជីកំប៉ុស្តិ៍បានហើយ ដោយសារតែវាអាចស្ងួយ៉ាងឆាប់រហ័ស។

## ១៣)ការប្រមូលផល

- ការប្រមូលផលគឺនៅពេលដែលពោតរបស់អ្នក បង្ហាញពីលក្ខណៈរូបសាស្ត្រទៅជាចាស់ ឬទុំ។ ជាធម្មតា ២ ខែបន្ទាប់ពីពីចេញពន្លកផ្កាមក។ ដើមរបស់វាមើលទៅចាប់ផ្តើមស្ងួតខ្លាំង ហើយផ្លែរបស់វាចាប់ផ្តើមស្រយ៉ុងចុះ។ នៅដំណាក់កាលនេះពោតនឹងបាត់បង់ជាតិទឹកប្រហែលជា ៣០ ភាគរយ។
- ត្រូវយកផ្លែពោតទៅសម្ងួតអោយធ្លាក់សំណើមមកត្រឹម ១៣ ភាគរយ ទើបយកវាទៅច្រកការ៉ុង ឬ ស្បោងទុកបាន។

## ១៤)ការរក្សាមែកពោតបន្ទាប់ពីប្រមូលផល

- អ្នកអាចជាន់ពីលើដើមពោតសង្កត់ វាទុកចោលនៅតាមចន្លោះជួរ។
- ការដែលនាំឲ្យអ្នកចំណេញនោះ គឺដោយសារតែដើមនិងស្លឹកទាំងនោះពុកផុយក្លាយជាជី ហើយជួយកាត់បន្ថយការដុះឡើងនៃស្មៅចង្រៃផងដែរ។
- វានឹងនាំឲ្យកាត់ផ្តាច់វដ្តជីវិតនៃដង្កូវស៊ីរូងដើមពោតដូចគ្នា។

# មូលហេតុទាំង ២០ ដែលយើងត្រូវធ្វើតាមរបៀបរបស់ព្រះជាម្ចាស់

*មូលដ្ឋានគោលនៃបច្ចេកទេស កសិកម្មតាមរបៀបព្រះជាម្ចាស់គឺ....*

| |
|---|
| ***ចូរកុំដុត ឬលាយបញ្ចូលកម្ទីចកម្ទីពុកផុយ<br>មិនត្រូវភ្ជួរដី, អនុវត្តន៍ដំណាំឆ្លាស់*** |

***ចូរកុំដុត....***

*កម្ទីចកម្ទីពុកផុយគឺជាការបង្ហាញអោយឃើញពីភាពសម្បូរហូរហៀរ ស្របតាមសេចក្តីសន្យារបស់ព្រះជាម្ចាស់។ កម្ទីចកម្ទីទាំងនោះវាបាជួយអោយបរិស្ថានសមស្របសម្រាប់ការកែប្រែដី។*

***ចូរកុំភ្ជួរដី.....***

*កាលពីសម័យដើមតាមព្រះគម្ពីបានសន្យាថា មនុស្សបានប្រើឈើស្រួចៗបុកជារណ្តៅ គឺមិនបានភ្ជួរត្រលប់ដីនោះទេ។ ប៉ុន្តែគ្រាន់តែជ្រោយដីអោយមានជម្រៅរាក់ល្មម ដើម្បីដាក់គ្រាប់ដំណាំតែប៉ុណ្ណោះ។*

***អនុវត្តន៍ដំណាំឆ្លាស់......***

*តាមការសិក្សាបានបង្ហាញថាការដាំដំណាំឆ្លាស់មានសារៈសំខាន់ក្នុងការ ជួយថែរក្សាដី និងធ្វើអោយដំណាំមានសុខភាពល្អ។*

*សារៈប្រយោជន៍នៃកសិកម្មតាមរបៀបព្រះជាម្ចាស់បានសង្ខេបដូចខាងក្រោមនេះ៖*

***សារៈប្រយោជន៍ទូទៅ***

១. **កាត់បន្ថយការហូរច្រោះដែលបណ្តាលមកពីទឹកភ្លៀង**

**កសិកម្មធម្មតា** ៖ ជាធម្មតាទឹកភ្លៀង ៩០% ត្រូវបានបាត់តាមរយៈរំហូរ។

**កសិកម្មតាមរបៀបព្រះជាម្ចាស់** ៖ ជាធម្មតាទឹកភ្លៀងតែ ៦% ប៉ុណ្ណោះដែលត្រូវបានបាត់តាមរយៈរំហូរ។

២. **កាត់បន្ថយសំណឹកដី**

**កសិកម្មធម្មតា** ៖ ជាធម្មតាដីបានបាត់បង់ចំនួនពី ៩៥ ទៅ ២២០ តោនក្នុងមួយហិចតានៅរយៈមួយឆ្នាំ (អាព្រិច)។

**កសិកម្មតាមរបៀបព្រះជាម្ចាស់** ៖ បានជួយកាត់បន្ថយការបាត់បង់ដីបន្តិចម្តងៗ ក្នុងមួយហិចតាជារៀងរាល់ឆ្នាំ។

៣. **ជួយឲ្យដីអាចជ្រាបទឹកបានល្អ**

**កសិកម្មធម្មតា** ៖ ពេលកម្លាំងទឹកភ្លៀងធ្លាក់ចុះមក មានទឹកភ្លៀងត្រឹមតែ ១០% ប៉ុណ្ណោះដែលអាចជ្រាបចូលទៅក្នុងដីបាន។

**កសិកម្មតាមរបៀបព្រះជាម្ចាស់** ៖ កម្ទីចកម្ទីស្លឹកឈើងាប់បានការពារដីពីកម្លាំងទឹកភ្លៀងដែលធ្លាក់ចុះមក ហើយក៏ធ្វើអោយដីធូរល្អ អាចស្រូបយក និងផ្ទុកជាតិទឹកបានរហូតដល់ទៅ ៩៤% ឯណោះ។

៤. **កាត់បន្ថយជាតិទឹកដែលបាត់បង់តាមរយៈរំហួត**

**កសិកម្មធម្មតា** ៖ ដីដែលគេភ្ជួរអាចជ្រាបជាតិទឹកបានត្រឹមតែ ១០%ប៉ុណ្ណោះ ហើយកម្រិតជាតិទឹកទាំងនោះស្ងួតទៅវិញយ៉ាងរហ័ស នេះបណ្តាលមកពីកម្តៅថ្ងៃ ខ្ពស់ពេក ដែលនាំអោយរំហួតកើនឡើងយ៉ាងខ្លាំងដូចគ្នា។

**កសិកម្មតាមរបៀបព្រះជាម្ចាស់** ៖ កម្ទីចកម្ទីស្លឹកឈើបានដើរតួនាទីជាគម្របដី វាមិនត្រឹមតែជួយបាំងជាម្លប់ប៉ុណ្ណោះទេ តែវាក៏បានជួយរក្សាសំណើមដែលមានក្នុងដី ធ្វើដីត្រជាក់ផងដែរ។ ដែលនាំអោយវាអាចជួយកាត់បន្ថយរំហួតដែលចេញពីដីមកបានយ៉ាងច្រើនគួរអោយកត់សម្គាល់។

**៥. រក្សាសីតុណ្ហភាពដីអោយត្រជាក់ ងាយស្រួលសម្រាប់កូនរុក្ខជាតិលូតលាស់ល្អ**

កូនរុក្ខជាតិដែលដាំតាមរយៈ កសិកម្មតាមរបៀបព្រះជាម្ចាស់ ដុះលូតលាស់នៅដំណាក់កាលដំបូងយឺតជាងគ្រាប់ពូជដែលដាំតាម កសិកម្មធម្មតា ។ ប៉ុន្តែ ៣ សប្តាហ៍ក្រោយពីវាបានចាក់ឫសហើយនោះ វានឹងលូតលាស់ល្អលឿនជាងកសិកម្មធម្មតា។ នោះដោយសារតែសីតុណ្ហភាពក្នុងដីត្រជាក់ វាជួយអោយកូនរុក្ខជាតិចាក់ឫសបានល្អ និងមានសុខភាពមាំមួន។

**៦. ចូរកុំបណ្តោយអោយភ្លៀងដើមរដូវត្រូវខ្ជះខ្ជាយឡើយ**

**កសិកម្មធម្មតា** ៖ រង់ចាំភ្លៀងដើមឆ្នាំធ្លាក់មកម្តងសិន ទើបចាប់ផ្តើមភ្ជួរដី រួចត្រូវរង់ចាំម្តងទៀតមុននឹងអាចដាំដុះបាន។

**កសិកម្មតាមរបៀបព្រះជាម្ចាស់** ៖ រៀបចំដីចម្ការរួចជាស្រេចមុនពេលភ្លៀងធ្លាក់ដើមឆ្នាំ។ លុះដល់ពេលភ្លៀងដើមឆ្នាំធ្លាក់មក គឺគេអាចចាប់ផ្តើមដាំដុះតែម្តង ព្រោះដីមានសំណើម មិនហួតហែងពេក។

**៧. ការជួយបង្ការស្មៅមិនឲ្យដុះ**

**កសិកម្មធម្មតា** ៖ ការភ្ជួរដីជម្រុញឲ្យស្មៅដុះកាន់តែច្រើន។

**កសិកម្មតាមរបៀបព្រះជាម្ចាស់** ៖ មិនមានការភ្ជួរដី និងយកកម្ទេចកម្ទីស្លឹកឈើ គ្របពីលើឲ្យជិត ១០០%ជួយបង្ការស្មៅមិនឲ្យដុះ។ ការគ្របកម្ទេចកម្ទីឲ្យរាបស្មើគឺជា វិធីសាស្ត្រមួយ ដ៏ល្អក្នុងការកំចាត់ពពួកស្មៅ។

*អត្ថប្រយោជន៍ក្នុងការក្សារគុណភាពដីអោយបានល្អ*

៨. **ការជួយឲ្យដីរក្សាជាតិទឹកបានយូរ**

*ដីដែលគេមិនភ្ជួររក្សាសំណើមបានល្អជាង ហើយជាលទ្ធផលគឺវាធន់នឹងភាពរាំងស្ងួត និងផ្តល់ទន្និផលបានខ្ពស់ជាង ។*

៩. **ការបង្កើនជីវជាតិឲ្យដី**

*កម្ទេចកម្ទីស្លឹកឈើបានពុកផុយបន្តិចម្តងៗពីមួយឆ្នាំទៅមួយឆ្នាំ តាមរយៈសកម្មភាពសត្វល្អិតតូចៗ ហើយនិងពពួកមីក្រូអតិសុខមប្រាណដ៏ទៃផ្សេងៗទៀត។ នេះគឺជាផ្នែកមួយដ៏សំខាន់ដើម្បីបញ្ចោញនូវសារធាតុចិញ្ចឹម ហើយផ្តល់ត្រលប់ទៅអោយដីវិញ។ តាមរយៈសកម្មភាពទាំងអស់នេះហើយ ដែលជួយបង្កើនជីវជាតិឲ្យដី ។*

១០. **ការប៉ះប៉ូវនូវធាតុអាសូតឡើងវិញតាមរយៈការដាំដំណាំឆ្លាស់ជាមួយ Legume**

*យើងអាចបង្កើនជីវជាតិតាមរយៈការដាំដំណាំឆ្លាស់ជាមួយនឹងពពួក Legume ដែលមានដូចជាពពួកសណ្តែកបាយ សណ្តែកសៀង សណ្តែកដី និងដាំណាំផ្សេងៗទៀត ដែលជួយប៉ះប៉ូវធាតុអាសូត។ ធាតុអាសូតនេះនឹងអំណោយផលល្អសម្រាប់ដំណាំនៅឆ្នាំបន្ទាប់ទៀត ។*

១១. **ការកាត់បន្ថយកំហាប់ដី**

**កសិកម្មធម្មតា** ៖ *ដីដែលភ្ជួររាយនឹងបាត់ជីវជាតិ ព្រោះពេលភ្ជួរម្តងៗធ្វើឲ្យដីក្រឡាប់បែកទ្រង់ទ្រាយ ខ្យល់ចេញចូលមិនបានល្អ ហើយធ្វើឲ្យដីកាន់តែឆាប់ហាប់ខ្លាំង។ ការភ្ជួរក៏បណ្តោលឲ្យដីស្រទាប់លើ កម្រាស់ពី ២០ - ៣០ សង់ទីម៉ែត្ររឹងក្តាំងផងដែរ ។*

***កសិកម្មតាមរបៀបព្រះជាម្ចាស់*** ៖ ពីមួយឆ្នាំទៅមួយឆ្នាំ ដីបង្កើនមាឌរបស់វា ហើយដោយមានឫសពីដំណាចាស់ៗ និងសរីរាង្គផ្សេងៗដែលរស់នៅលើនោះ វាអំណោយផលដល់ដំណាំ សម្រាប់ឆ្នាំបន្ទាប់ទៀតឲ្យចាក់ឫសបានល្អ ។

**១២.** ***ជួយឲ្យដីមានខ្យល់ចេញចូល***

*ដីដែលមិនភ្ជួរនាំឲ្យសរីរាង្គងាយរស់នៅ ហើយសរីរាង្គតូចៗ និងសារជាតិ រលួយទាំងនោះដើរតួនាទីយ៉ាងសំខាន់ ក្នុងការនាំខ្យល់ចេញចូលក្នុងដីហើយនាំ ឲ្យឫសរបស់ដំណាំស្រូបយកខ្យល់បានល្អ ទោះបីជាមានទឹកដក់ជាប់ក៏ដោយ ។*

**១៣.** ***បង្កើនពពួកអតិសុខុមជីវសាស្ត្រក្នុងដី***

*នៅក្នុងដីមានពពួកអតិសុខុមជីវសាស្ត្រ ២ ប្រភេទធំៗគឺ៖ ពពួករស់នៅដោយត្រូវការខ្យល់ និងពពួករស់នៅដោយមិនត្រូវការខ្យល់។*

***កសិកម្មធម្មតា*** ៖ *ពេលគេភ្ជួរដីម្តងៗនាំឲ្យពពួកសរីរាង្គជីវៈដែលត្រូវការខ្យល់ កប់លិចក្នុងអាចម៍បំណាស់ ចំណែកពពួកដែលមិន ត្រូវាការខ្យល់ហើបចេញមកក្រៅ ជាលទ្ធផលនាំឲ្យពួកវាងាប់ទាំងពីរ ។*

***កសិកម្មតាមរបៀបព្រះជាម្ចាស់*** ៖ *ដោយសារមិនជុត ឬភ្ជួរដី ធ្វើឲ្យដីត្រជាក់និងមានសំណើម ដែលនាំឲ្យសម្បូរ សរីរាង្គតូចៗ រស់នៅក្នុងដី ដែលមានសុខភាពល្អ គឺជាដីដែលមានជីវិត ។*

## អត្ថប្រយោជន៍ផ្នែកសេដ្ឋកិច្ច

### ១៤. ការគ្រប់គ្រងសត្វល្អិត និងជម្ងឺ

ដំណាំដែលស្ថិតក្រោមសំពាធខ្វះជីវជាតិ និងសំណើមស្រូបយកពន្លឺថ្ងៃមិនសូវបានល្អ ដែលជាមូលហេតុងាយនាំឲ្យឆាប់កើតជម្ងឺ និងរងនូវការបំផ្លាញពីសត្វល្អិត។

***កសិកម្មតាមរបៀបព្រះជាម្ចាស់*** ៖ ធ្វើអោយដំណាំមានសុខភាពល្អរឹងមាំ មិនស្ថិតក្រោមសម្ពាធ ។ វាក៏ជួយរក្សានូវតុល្យភាពក្នុងប្រព័ន្ធអេកូឡូស៊ី គឺបង្កើតឲ្យមានសត្វល្អិតមានប្រយោជន៍ ដែលពួកវានឹងស៊ីសត្វល្អិតដែលបំផ្លាញដំណាំ។ ការអនុវត្តន៍នូវដំណាំឆ្លាស់ក៏ជួយកាត់ផ្តាច់នូវវដ្តជីវិតនៃសត្វល្អិតចង្រៃ ហើយនិងជម្ងឺផងដែរ។ ហើយមិនត្រឹមតែប៉ុណ្ណោះទេ វាក៏ជួយកាត់បន្ថយកុំអោយដំណាំបាត់បង់តាមរយៈការផ្ទុះនូវអត្រាសត្វល្អិតចង្រៃទៀតផង។

### ១៥. កាត់បន្ថយពេលវេលា និង ការចំណាយទៅលើការរៀបចំដីចម្ការ

តាមកសិកម្មធម្មតា កសិករដែលមានដីចម្ការធំៗ ត្រូវការចំណាយទ្វេដាបី ទៅលើថ្លៃសាំង ប្រេង ការជួលជុល និងថ្លៃថែទាំគ្រឿងម៉ាស៊ីន បើប្រៀបជាមួយកសិកម្មកសិករដែលមិនភ្ជួររាស់ដី។ កសិករតូចៗវិញត្រូវចំណាយពេលដល់ទៅ ១០ អាទិត្យដើម្បីភ្ជួររាស់ រៀបចំដីចម្ការ ប៉ុន្តែកសិកម្មតាមរបៀបព្រះជាម្ចាស់វិញ គឺយើងចំណាយពេលត្រឹមតែ ៦ អាទិត្យប៉ុណ្ណោះ ក្នុងការរៀបចំដី ឲ្យរួចជាស្រេចដើម្បីទុកដាំគ្រាប់ពូជ។

### ១៦. កាត់បន្ថយការបាត់បង់ដី

ជារៀងរាល់ឆ្នាំ មានដីរាប់លានតោនត្រូវបានបាត់បង់តាមរយៈទឹកហូរ ការលិចជ្រាប និងការហូរច្រោះ។ កសិកម្មតាមរបៀបព្រះជាម្ចាស់ជួយទប់ស្កាត់ការ

បាត់បង់ដី ហើយការដាក់ដីរបស់យើងគឺយើងដាក់ក្បែរតែកន្លែងដែលដំណាំបានចាក់ឫសប៉ុណ្ណោះ ។

## ១៧. ធ្វើអោយដីធន់និងភាពរាំងស្ងួត និងទប់ស្កាត់ការរាលដាលនៃហានិភ័យ

ការធន់និងភាពរាំងស្ងួតរបស់ដីវាអាស្រ័យទៅលើកត្តាបីយ៉ាងគឺ៖

- បរិមាណនៃកម្ទេចកម្ទីដែលបានគ្របពីលើដី
- អាហ្រ្គីហ្គេតដី ឬទម្រង់ដុំដីតូចៗល្អ
- បរិមាណនៃសារពាង្គកាយមានជីវិតដែលអាចរកឃើញនៅក្នុងដី។

ការអនុវត្តន៍ដំណាំឆ្លាស់ មួយភាគបី គឺជួយកុំអោយយើងមានហានិភ័យនៃការបាត់ទិន្នផលដំណាំសរុប នៅពេលដែលមានគ្រោះមហន្តរាយដូចជា៖ គ្រោះរាំងស្ងួត ឬការផ្ទុះឡើងនូវអត្រាសត្វល្អិតក្នុងតំបន់។

## ១៨. ការកាត់បន្ថយថ្លៃចំណាយលើប្រព័ន្ធធារាសាស្ត្រ

កសិកម្មតាមរបៀបរបស់ព្រះជាម្ចាស់ គឺធ្វើអោយដំណាំមិនត្រូវការ ស្រោចទឹកច្រើនដងទេ ដោយសារតែដីរក្សាសំណើមជាប់បានយូរ មកពីការមិនភ្ជួររាស់ និងដោយសារមានកម្ទេចកម្ទីស្លឹកឈើគ្របពីលើ ។

## ១៩. ការបង្កើនប្រសិទ្ធិភាពដំណាំ

កសិកម្មតាមរបៀបព្រះជាម្ចាស់បានផ្តល់ឲ្យនូវបរិស្ថានល្អ សម្រាប់ដំណាំអាចរីកលូតលាស់បានខ្លាំង ដោយធ្វើអោយវាមានសម្ពាធ ដូចនេះនាំអោយទិន្នផលបានខ្ពស់ឡើងផងដែរ។ ដោយឫសបានដុះលូតលាស់ចាក់ចូលទៅក្រោមកម្ទីចកម្ទីពុកផុយដោយផ្ទាល់ ដែលសារធាតុពុកផុយទាំងអស់នោះមានផ្ទុកនូវជីវជាតិដ៏សម្បូរបែប ព្រមទាំងសំណើមក៏មានកម្រិតខ្ពស់ផងដែរនោះ វាបានជួយភ្ញោចដល់ឫសអោយធ្វើសកម្មភាពកាន់តែខ្លាំងក្លាឡើង។

## ២០. ការបង្កើនបរិមាណទិន្នផល

ឪពុកលោក **ឌីស៊ុន** (Dixon) ទទួលបានផលជាមធ្យម ៣ប៉ាវក្នុង១ឆ្នាំ។ ពេលលោក **ឌីស៊ុន**(Dixon) ទទួលដីនេះជាមរតក គាត់បានផ្លាស់ប្តូរពីកសិកម្មធម្មតា ទៅជាកសិកម្មតាមរបៀបព្រះជាម្ចាស់។

លោក ដុកសិនទទួលផល

- ឆ្នាំទី១ ទទួលបាន ៥ បាវ
- ឆ្នាំទី២ ទទួលបាន ៤៥ បាវ
- ឆ្នាំទី៣ ទទួលបាន ៥៤ បាវ
- ឆ្នាំទី៤ ទទួល ៦៩ បាវ

លោក **យ៉ូសែប** ទទួលបានពី ៧ ទៅ ៧0 បាវនៅឆ្នាំ ទី១ ។

ចំណែកលោក **ជោច** ទទួលបានផល ៩ដង ច្រើនជាងមុន ។

# ការគ្រប់គ្រង

គោលបំណងនៃការគ្រប់គ្រងនៅក្នុងកសិកម្មតាមរបៀបព្រះជាម្ចាស់គឺ ចង់បង្កើនឲ្យមានផលចំណេញដែលស្ថិតស្ថេរ ។ នៅក្នុងកសិកម្មតាមរបៀបព្រះជាម្ចាស់ មានចំណុចតូចសំខាន់ៗ ជាច្រើនដែលយើងអាចសន្សំសំចៃបានរួមមានដូចជា ដី ជាតិសំណើម ជីវជាតិ ពេលវេលានៃការរៀបចំដី នឹងថ្លៃផ្សេងៗ ។ ដើម្បីអនុវត្តន៍កសិកម្មតាមរបៀបព្រះជាម្ចាស់ឲ្យ បានជោគជ័យយើងត្រូវពង្រឹងលើការគ្រប់គ្រង ។

**មានគន្លឹះសំខាន់ៗ ៣យ៉ាងក្នុងការគ្រប់គ្រង កសិកម្មតាមរបៀបព្រះជាម្ចាស់គឺ**

**ធ្វើឲ្យទាន់ពេលវេលា ធ្វើឲ្យខ្ពស់តាមស្តង់ដា និងមិនខ្ជះខ្ជាយៗ**

## គន្លឹះទី ១ ការធ្វើអោយទាន់ពេលវេលា

- កំណើតពិភពលោកជំពូកទី ១ ៖ ១៤ ~ ១៩ ស្នាព្រះហស្តបង្កើតដំបូងបង្អស់របស់ព្រះជាម្ចាស់គឺ ជាចំណុចមួយនៃ ការកំណត់ពេលវេលា
- ព្រះជាម្ចាស់បានបង្កើតឲ្យ មានថ្ងៃ ខែ ឆ្នាំ និងរដូវកាល
- សាស្តាជំពូកទី ៣ ៖ ១១ " អ្វីៗដែលព្រះអង្គធ្វើសុទ្ធតែល្អស្អាតតាមពេលរបស់វា"
- រៀបចំដីចម្ការ នៅពេលទំនេរក្រោយពីប្រមូលផលរួច
- ប្រមូលលាមកគោ កម្ទេចកម្ទី និងគ្រាប់ពូជទុក
- បង្កើតជីកំប៉ុស្តិ៍ ទុកជាស្រេចមុនពេល រដូវកាលដំដុះចូលកមដល់ ។

- ដាំឲ្យទាន់ពេលវេលា នៅអាហ្វ្រិកភាគខាងត្បូង នៅតំបន់ដែលមានភ្លៀងចាប់ផ្តើមធ្លាក់ នៅរដូវក្តៅ ប្រសិនបើអ្នកដាំដំណាំយឺតចាប់ពីក្រោយ ថ្ងៃទី ២៥ ខែវិច្ឆិកា ទៅអ្នកនិងខាត ទិន្នផលចំនួន ១២០ គីឡូក្រាមក្នុងមួយថ្ងៃ ។
- បោចកម្ចាត់ស្មៅឲ្យទាន់ពេល ។

## គន្លឹះទី ២ ដំណើរទៅរក ស្តង់ដារខ្ពស់

អ្វីៗគ្រប់យ៉ាងដែលព្រះជាម្ចាស់ធ្វើ គឺព្រះអង្គធ្វើត្រូវតាមស្តង់ដារខ្ពស់ យើងអាចឃើញពី ស្តង់ដារល្អឥតខ្ចោះ របស់ព្រះអង្គមុនគេបង្អស់ តាមរយៈស្នាព្រះហស្តបង្កើតរបស់ព្រះអង្គ នៅក្នុងសៀវភៅកំណើតពិភពលោកជំពូកទី១ ដែលព្រះអង្គបានបង្កើតរួចទតឃើញថាអ្វីៗ ដែលព្រះអង្គបង្កើតមកនោះគឺល្អ ។

- ខ្សែរបន្ទាត់ ត្រូវត្រង់ជួរ និងគំលាតពីមួយទៅ មួយគឺត្រឹមត្រូវ
- តម្រុយចំណាំជាអចិន្ត្រៃយ៍ ត្រូវបោះឲ្យចំកន្លែងដដែលៗពីមួយឆ្នាំទៅមួយឆ្នាំ
- រណ្តៅ ត្រូវមានចន្លោះ៦០ × ៧៥ ដោយមានជម្រៅទៅតាមប្រភេទដំណាំ
- ដំពោត ៣ គ្រាប់ក្នុង ១រណ្តៅ
- ចំនួនដើមពោតសរុប ៤៤ ៤៤៤ ដើមក្រោយពីជម្រុះរួច
- ចូរកំចាត់ស្មៅជាប្រចាំកុំឲ្យដុះ
- ចូរដាក់អ្វីគ្រប់យ៉ាងឲ្យបានត្រឹមត្រូវ

### មូលហេតុនៃការដាំនៅក្នុងរណ្តៅដដែលៗពីមួយឆ្នាំទៅមួយឆ្នាំ

- ជីវជាតិដែលនៅសេសសល់ពីឆ្នាំមុនអំណោយផលល្អដល់ដំណាំនៅឆ្នាំបន្ទាប់
- ធ្វើអោយមាឌដី ទន់ហើយនឹងងាយអោយរុក្ខជាតិលូតលាស់ល្អជាង។

- ដោយសារតែឫសដំណាំមុនៗរលាយធ្វើអោយដីកាន់តែមានជីវជាតិ និងបន្សល់ជាច្រកងាយដល់ការចាក់ឫស និងជ្រាបទឹកសម្រាប់ដំណាំបន្ទាប់។
- ដីហាប់ណែនតែចំពោះចន្លោះរងដំណាំប៉ុណ្ណោះ។
- ដីចន្លោះពីដំណាំមួយទៅមួយទទួលការរំខានតិចតួចប៉ុណ្ណោះ ហើយក៏ជួយកាន់បន្ថយការដុះរបស់ស្មៅផងដែរ។

ស្តង់ដារនៃរង្វាស់រង្វាល់និមួយៗ គឺដើម្បីអោយមានគុណភាពល្អ មិនមែនដើម្បីភាពល្អឥតខ្ចោះនោះឡើយ។ ស្តង់ដារនិមួយៗត្រូវបានធ្វើឡើងយ៉ាងប្រុងប្រយ័ត្នបំផុតដើម្បីផ្តល់អោយកសិករទទួលបានផលចំណេញដ៏ស្ថិតស្ថេរ។

- កូឡូស ជំពូកទី ៣៖២៣ "គ្រប់កិច្ចការដែលបងប្អូនធ្វើ ចូរធ្វើអោយអស់ពីចិត្ត ដូចធ្វើថ្វាយព្រះជាម្ចាស់ដែរ គឺមិនធ្វើសម្រាប់មនុស្សលោកទេ"

## គន្លឹះទី ៣ មិនត្រូវខ្ជះខ្ជាយឡើយ

បើមើលនៅក្នុងព្រះគម្ពីរ យើងឃើញរឿងមួយដែលបង្រៀន យើងកុំឲ្យខ្ជះខ្ជាយនោះគឺរឿងពេលព្រះ យេស៊ូ ផ្តល់អាហារឲ្យមនុស្សប្រាំពាន់នាក់ (ម៉ាថាយជំពូកទី ១៤ ៖ ១៤)

**ឧទាហរណ៍បង្ហាញពីភាពមិនខ្ជះខ្ជាយរបស់ព្រះជាម្ចាស់**

- វដ្តទឹក
- វដ្តការបូន

**ភាពខ្ជះខ្ជាយរបស់មនុស្ស ៖**

- ការកាប់បំផ្លាញព្រៃ
- ការកាប់ឆ្ការ និងដុតព្រៃធ្វើកសិកម្ម
- ដីសឹករិចរិល
- ការហូរច្រោះ
- ការធ្វើដីកសិដ្ឋានធំ តែបានផលតិចគឺជាភាពខ្វះខ្នាយ

*កសិកម្មតាមរបៀបព្រះជាម្ចាស់ជួយកាត់បន្ថយភាពខ្វះខ្នាយដោយ៖*

- បន្ថយតម្រូវការប្រើប្រាស់ដី តាមរយៈការបង្កើន ទិន្នផលលើទំហំប៉ុនគ្នា
- ជួយរក្សាដី
- ធ្វើឲ្យដីជ្រាបទឹកបានល្អ
- កាត់បន្ថយការហូរច្រោះដី
- ជួយរក្សាសំណើមដី
- ផ្ដល់ជីឲ្យដីតាមរយៈវដ្ដវិលចុះឡើង នៃសារធាតុចិញ្ចឹមធម្មជាតិ
- រាល់សម្ភារៈត្រូវបានប្រើប្រាស់ប្រកបដោយប្រសិទ្ធិភាព
- ជួយសន្សំពេលវេលា និងថវិការ។

# សេចក្ដីសន្និដ្ឋាន

វាជារឿងមួយដ៏អស្ចារ្យនៅពេលយើង យកគន្លឹះទាំង ៣ នៃការគ្រប់គ្រងនេះទៅអនុវត្តន៍ ត្បិតយើងនិងមានក្ដីអំណរ យ៉ាងខ្លាំងជាមួយ ស្នាដៃដែលយើងធ្វើ ។ ចូរចង់ចាំថា ប្រសិនបើអ្នកសាបព្រោះដោយក្ដីអំណរ អ្នកក៏និងប្រមូលផលវិញ ដោយក្ដីអំណរដែរ។ ប្រសិនបើអ្នក សាបព្រោះដោយមុខក្រញ៉ាំក្រញ៉ូវ រអ៊ូរទាំនោះ អ្នកក៏នឹងប្រមូលផលវិញដោយបែបនោះដែរ ។

- កូរិនថូសទី ២ ជំពូក ៩ ៖ ៧ "ចូរឲ្យគ្រប់គ្នាធ្វើតាមដែល សម្រេចក្នុងចិត្តចុះមិនមែនដោយស្ដាយ ឬដោយបង្ខំឡើយ ដ្បិតព្រះទ្រង់ស្រលាញ់ដល់អ្នកណា ដែលថ្វាយដោយអំណរ "

ការប្រាថ្នាចង់បានការគ្រប់គ្រងល្អ និងផលចំណោញស្ថិតស្ថេរគឺ ជារឿងបន្ទាប់បន្សំគឺវា មិនស្មើនឹង តម្លៃដែលយើងជាបុត្ររបស់ព្រះជាម្ចាស់ និងបង្ហាញពីផលផ្លែនៃព្រះវិញ្ញាណបរិសុទ្ធ ដើម្បីជាការសម្ដែងឲ្យឃើញពី អំណាចព្រះជាម្ចាស់ ក្នុងការផ្លាស់ប្ដូរជីវិតមនុស្ស។

# ការធ្វើជីកំប៉ុស្តិ៍

## សេចក្តីណែនាំ

- ជីកំប៉ុស្តិ៍គឺជាសមាសធាតុសរីរាង្គដែលបានពុកផុយ ដោយសារតែការបំបែករបស់ពពួកមីក្រូសារពាង្គកាយ ជាពិសេសគឺពពួក បាក់តេរី និងផ្សិត។
- ជីនេះជាជម្រើសដ៏អស្ចារ្យមួយ តាមរយៈការប្រើជីកំប៉ុស្តិ៍នេះ វាធ្វើអោយដីកាន់តែល្អឡើងៗពីមួយឆ្នាំទៅមួយឆ្នាំ។ បើប្រៀបធៀបទៅនឹងការប្រើប្រាស់ជីអសរីរាង្គសុទ្ធ ការប្រើប្រាស់ជីសរីរាង្គនេះ វាបានផ្តល់ប្រាក់ចំណេញទ្វេដង ទាំងទិន្នផលនិងការចំណាយ ក្នុងរយៈពេលយូរ។
- ជីកំប៉ុស្តិ៍ជួយបង្កើនកម្រិតសារធាតុចិញ្ចឹមក្នុងដី និងជួយរក្សាតុល្យភាពនៃពពួកមានជីវិតនៅក្នុងដី ។
- តាមរយៈការណែនាំរបស់អ្នកជំនាញដែលផ្តល់អោយ រោងកំប៉ុស្តិ៍គួរចាប់ផ្តើមធ្វើដំបូងនៅទំហំ ២ម × ២ម × ២ម (2m$^3$)។
- នៅពេលអ្នកធ្វើរោងជីកំប៉ុស្តិ៍ទៅតាមទំហំដែលបានកំណត់នេះ គឺវាគ្រប់គ្រាន់សម្រាប់ការដាំដំណាំពោតក្នុងទំហំផ្ទៃដី ១acre ឬកន្លះហិចតាហើយ។
- មិនត្រូវបន្ថយរោងជីកំប៉ុស្តិ៍ មកពីត្រឹម ឬក្រោម ១.៥ ម× ១.៥ម ×១.៥ម
- ចូរចាប់ផ្តើមប្រមូលវត្ថុធាតុសម្រាប់ធ្វើជាជីកំប៉ុស្តិ៍នៅជិតរោងដំណាំ នៅពេលដែលវត្ថុធាតុកំពុងតែសម្បូរនៅឡើង។

<u>ធាតុដែលចូលរួមផ្សំ</u>

ជីកំប៉ុស្តិ៍ គឺផ្សំឡើងពីសារធាតុ សំខាន់ៗ ៣ យ៉ាងគឺ៖ **សារធាតុអាសូត**, **សមាសភាគផ្សំពណ៌បៃតង** និង**សមាសភាគផ្សំពណ៌ត្នោត** ។



### សារធាតុអាសូត

- ដាក់អាសូតចំនួន ១០% នៃជីកំប៉ុស្តិ៍/លាមកគោ ១៥ ប៉ាវ
- ប្រសិនជាអត់មានលាមកគោទេ ត្រូវប្រើរុក្ខជាតិពពួក លីហ្គោម(legumes) ចំនួន ៤ ម៉ែត្រគូប(4m$^3$) ជំនួសវិញ។



### សមាសភាគផ្សំពណ៌បៃតង

- ចូរដាក់សមាសភាគបៃតង ចំនួន ៤៥% នៃជីកំប៉ុស្តិ៍
- ស្លឹក ឬ ដើមអ្វីក៏បានឲ្យតែពណ៌បៃតង ទោះបីជាវាក្រៀមស្ងួតហើយ ក៏ដោយ



### សមាសភាគផ្សំពណ៌ត្នោត

- ចូរដាក់សមាសភាគផ្សំពណ៌ត្នោត ៤៥% នៃកំប៉ុស្តិ៍
- ពពួកឈើស្ងួតជួយឲ្យពពួកផ្សិតអាចលូតលាស់បាន។ ឧទាហរណ៍ដូចជា ស្នូលពោត ដើមឈើ មែកឈើ ក្រដាសរឹងៗ និង ស្របកឈើ ។
- ពពួកដើមស្ងួតៗ ដូចជាស្បូវស្លឹក ឈើនិងស្មៅងាប់ៗ ជួយឲ្យជីកំប៉ុស្តិ៍កើនកាន់តែច្រើន ។

ត្រូវប្រមូលធាតុផ្សំ និមួយៗដាក់កន្លែងផ្សេងពី គ្នារង់ចាំដល់ពេលប្រមូលបានគ្រប់ចំនួន ហើយចាំលាយបញ្ចូលគ្នាក្នុងកន្លែងតែមួយ ។

❖ **ការសង់គំនរជីកំប៉ុស្តិ៍**

- ការរក្សាទំហំនៃគំនរកំប៉ុស្តិ៍ឲ្យស្មើគ្នាវាពិតជាសំខាន់ណាស់។
- ត្រូវដាក់ធាតុទាំង ៣ ជាជាន់ៗឆ្លាស់គ្នានៅក្នុងគំនរកំប៉ុស្តិ៍
- ត្រូវដាក់ត្រាំរុក្ខជាតិបៃតង និងឈើស្ងួតក្នុងទឹកមុននិងដាក់ចូលក្នុងគំនរកំប៉ុស្តិ៍
- ដំបូងត្រូវដាក់ឈើស្ងួតៗកម្រាស់ ២០ស.ម បន្ទាប់មកដាក់រុក្ខជាតិបៃតងកម្រាស់ ២០ស.មទៀត រួចហើយទើបដាក់លាមកគោដែលសើមឬក៏ផ្សើមទឹកហើយចំនួន ២ បាវពីលើទៀត។
- ចូរបន្តដាក់វាជាបន្តបន្ទាប់ជាស្រទាប់ៗរហូតដល់អ្នកបានកម្ពស់ ២ម៉ែត្រ។



## ❖ សីតុណ្ហភាព

- សីតុណ្ហភាពជាមធ្យមចន្លោះពី ៥៥ ទៅ៦៨ សង្សាសេ។
- ចូររក្សាសីតុណ្ហភាពស្ថិតនៅចន្លោះបែបនេះក្នុងរយៈពេល ៣ថ្ងៃ ដើម្បីឲ្យគ្រាប់ស្មៅ និងធាតុបង្កជម្ងឺផ្សេងៗងាប់។
- ត្រូវប្រើឧបករណ៍វាស់សីតុណ្ហភាព ដើម្បីវាស់កំដៅបានត្រឹមត្រូវ។
- បើគ្មានឧបករណ៍វាស់ គឺយើងអាចយកដែកដើមប្រវែង ៨ មីលីម៉ែត្រ យកទៅចាក់ចូលក្នុងគំនរកំប៉ុស្តិ៍ទុករយៈពេល ៣ ~ ៤ នាទី។ ពេលដកចេញមកវិញប្រសិនជាអ្នកអាចកាន់ដែកនោះបានរយៈពេល ៥ វិនាទីនោះមានន័យថាសីតុណ្ហភាពក្នុងនោះគឺតិចជាង ៧០ សង្សាសេ។ តែប្រសិនជាដែកនោះក្តៅពេកកាន់ ៥ វិនាទីមិនបាននោះមានន័យថាដល់ពេលដែលអ្នកត្រូវប្រែគំនរកំប៉ុស្តិ៍ហើយ ។
- ប្រសិនបើសីតុណ្ហភាពឡើងខ្ពស់ជាង ៧០សង្សាសេ នោះនឹងនាំពពួកមីក្រូអតិសុខមប្រាណដែលយើងចង់បានទៅជាងាប់ ហើយសារធាតុកាបូនបានឆេះអស់និងខ្ជះខ្ជាយ ។
- ជីកំប៉ុស្តិ៍ដែលគ្រាប់កំណាត់គួតែចុះត្រជាក់បន្ទាន់ពី ៦ ទៅ ៨ សប្តាហ៍។

## ❖ របៀបប្រែគំនរជីកំប៉ុស្តិ៍

- ការប្រែលើកទី ១ គឺ ៣ ថ្ងៃ (មុនសីតុណ្ហភាពឈានដល់ ៧០សង្សាសេ)
- ចូរយកសមធំ ឬចបកាប់ ទៅកាយច្របល់គំនរចូលគ្នា ២ម×២ម ទាញយកផ្នែកខាងក្រៅ ទៅដាក់ខាងក្នុង និងពីខាងក្នុងទៅដាក់ខាងក្រៅវិញ
- ការប្រែបែបនេះជួយឲ្យគំនរកំប៉ុស្តិ៍ មានសីតុណ្ហភាពត្រឹមត្រូវ ជីវជាតិរលាយចូលគ្នា គំនរនៅខាងក្រៅចូលទៅក្នុង ឲ្យត្រូវសីតុណ្ហភាពខ្ពស់និងឲ្យគំនរកំប៉ុស្តិ៍ទាំងមូល មានខ្យល់អុកស៊ីសែន ចេញចូល ហើយអាចឲ្យ យើងពិនិត្យឃើញជាតិសំណើម និងអាចតម្រែតម្រូវបានប្រសិនបើចាំបាច់ ។

- ប្រសិនបើមិនប្រែទេ វានិងហប់ខ្យល់ នាំអោយមានក្លិនស្អុយ ហើយដីកំប៉ុស្តិ៍ខូចគុណភាព។
- របៀបប្រែដីសាមញ្ញា គឺប្រែ ៣ ដងដំបូងរៀងរាល់ ៣ថ្ងៃម្តង រួចប្រែ៤ ទៅ ៥ ដង រៀងរាល់ ១០ ថ្ងៃម្តង។
- ដំណើរការនៃការប្រែដីកំប៉ុស្តិ៍និងចប់សព្វគ្រប់ក្នុងរយៈពេល ២ខែ។
- ក្រោយពីចប់ហើយទុកកន្លែងកំប៉ុស្តិ៍នោះឲ្យជាសះសម្រាប់ប្រើរយៈពេល ៤ ខែទៀត

❖ កម្រិតជាតិសំណើម

- សំណើមត្រូវបានបាត់តាមរយៈការសាយភាយទៅបរិយាកាស ដូចនេះហើយអ្នកត្រូវការបំពេញឡើងវិញ។
- ចូរព្យាយាមរក្សាសំណើមក្នុងដីកំប៉ុស្តិ៍របស់អ្នកអោយនៅត្រឹម ៥០%។ អ្នកអាចសាកល្បងពិនិត្យមើលសំណើមបានរយៈ ការយកវាមកពូតនិងដៃ។ បើពូតរួចហើយមានទឹកស្រក់ចេញមកនោះ មានន័យថាវាសើមពេក តែបើពូតរួចហើយគ្មានទឹកស្រក់ ហើយគ្មានឃើញស្នាមដៃពូតមានន័យ ថាវាស្ងួតខ្លាំងពេក ដូចនេះត្រូវដាក់ទឹកថែម។ បើពូតហើយគ្មានស្រក់ទឹកចេញ ហើយឃើញស្នាមដៃពូត ទៀតនោះបញ្ជាក់ថា វាមានជាតិសំណើម ៥០% តាមការចង់បានរបស់អ្នក ។
- ចូរទុកគំនរកំប៉ុស្តិ៍នៅកន្លែងដែលមានជម្រាលតែមិនចោតទេ ដោយគ្របពីលើវាដោយស្បូវ ឬក៏ការ៉ុងសម្រាប់ដាក់គ្រាប់ពូជ ពីលើក៏បាន។ ដើម្បីជៀសវាងសីតុណ្ហភាពក្នុងគំនរកំប៉ុស្តិ៍ចុះត្រជាក់ជ្រុលពេកពេលមានភ្លៀងធ្លាក់ខ្លាំងម្តងៗ។

- **ជីកំប៉ុស្ដិ៍ដែលល្អគឺ៖**
  - *មានពណ៌ត្នោតចាស់*
  - *មានក្លិនក្រអូបភាយ*
  - *មានលក្ខណៈរាងខ្ទេចៗ*
  - *ឃើញពពួកផ្សិតស្មៅ*
  - *អាចរក្សាទុករាប់ឆ្នាំដោយមិន ធ្លាក់ឬបាត់បង់សារជាតិចញ្ចឹមរបស់វា*

*គ្រប់កសិដ្ឋានទាំងអស់គួប្រើជីកំប៉ុស្ដិ៍ដើម្បី ជាការបង្ហាពីសេចក្ដី ស្មោះត្រង់ចំពោះភាព សម្បូរហូរហៀដែលព្រះជាម្ចាស់ប្រទានដល់ដៃរបស់យើង។*

# ជីវៈចម្រុះតាមប្រភេទដំណាំខុសៗគ្នា

នៅក្នុងកសិកម្មតាមរបៀបព្រះជាម្ចាស់ យើងជម្រុញទឹកចិត្តឲ្យកសិករ អនុវត្តន៍ជីវៈចម្រុះ តាមរយៈការដាំដំណាំឆ្លាស់ ការដាំដំណាំបណ្តាក់វេន ឬដំណាំគម្របដី (ដំណាំជីស្រស់)។

## ការផ្លាស់ប្តូរប្រភេទដំណាំ

- ដំណាំគួរផ្លាស់ប្តូរវៀងរាល់ ៣ឆ្នាំម្តង។
- ចូរចែកដីចម្ការទៅជា ៣ ប្លង់ប៉ុនៗគ្នា ប្លង់ទី ១ និង ទី២ ទុកដាំដំណាំចាំបាច់ ដូចជាពោត ហើយប្លង់ទី៣ ទុកដាំដំណាំឆ្លាស់ ដូចជាសណ្តែកខៀវ ។

| ឆ្នាំ | ទី១ | ទី២ | ទី៣ |
|---|---|---|---|
| ប្លង់ទី១ | ពោត | សណ្តែក | ពោត |
| ប្លង់ទី២ | ពោត | ពោត | សណ្តែក |
| ប្លង់ទី៣ | សណ្តែក | ពោត | ពោត |

- ចូរទុកដីទំហំ ១/៣ នៃចម្ការសម្រាប់ដាំដំណាំឆ្លាស់
- ការដាំដំណាំឆ្លាស់គឺជួយកំចាត់ជម្ងឺ និងវដ្តជីវិតសត្វល្អិតចង្រៃ ហើយក៏ជួយឲ្យទម្រង់និងជីវជាតិដី មានលក្ខណៈល្អប្រសើរដែរ។ មិនត្រឹមតែប៉ុណ្ណោះទេដំណាំឆ្លាស់ប្រៀបបាននឹងរបបអាហារ ដែលផ្តល់ឲ្យយើងទាំង ប្រូតេអ៊ីន និងវីតាមីន និងជួយបញ្ចៀសយើងពីហានិភ័យផ្នែកហិរញ្ញវត្ថុផងដែរ ។

## គោលការណ៍ណែនាំទូទៅនៃការផ្លាស់ប្តូរប្រភេទដំណាំ

- ប្តូរពីដំណាំតែមួយមុខ ទៅជាដំណាំច្រើនមុខខុសៗគ្នា

- ការដាំដំណាំពពួកបន្លែងដូចជា សណ្ដែក សណ្ដែកសៀង សណ្ដែកបារាំង សណ្ដែកបាយ សណ្ដែកផ្អែម សណ្ដែកដី។ យើងក៏អាចបញ្ចូលដំណាំផ្សេងទៀត ដូចជា ដំឡូងផ្អែម បន្លែ និងផ្កាឈូករត្ន័ ។
- នៅលើប្លង់ទី ៣ ដែលទុកដាំដំណាំឆ្លាស់ យើងអាចបែកចែកវាទៅជាប្លង់តូចៗទៀត ដើម្បីដាំបន្លែផ្សេងៗទៀត ជារូបត្ថម្ភបន្ថែម សម្រាប់គ្រួសារ ។




Example of a field rotation

❖ ***ការដាំដំណាំបណ្ដាក់គ្នា***

*ដំណាំបណ្ដាក់គ្នា គឺជាការដាំដំណាំទី២ បន្ទាប់ពីប្រមូលផលដំណាំទី២ រួច យើងអាចដាំបែបនេះបានលុះត្រា អាកាសធាតុ តំបន់នោះមានលក្ខណៈអំណោយផល ឬ មានសំណើមជាប់ រហូតដល់ចប់រដូវ ។ ដំណាំបណ្ដាក់គ្នាគឺខុសពី ដំណាំឲ្យផលទ្វេរដង ត្បិតយើងដាំវា បន្ទាប់ពីប្រមូលផលដំណាំ មួយទៀតរួចរាលសិន ។ ចូរប្រុង*

ប្រយ័ត្ន មិនត្រូវដាំដំណាំទី១ឆាប់ពេកនោះទេ ព្រោះវាអាចខាត ទិន្នផល ដំណាំទី១ ជាពិសេ ពេលវាកំពុងរៀបចំ ដាក់គ្រាប់ ។ ឧ. មិនត្រូវដាំ សណ្តែកបាំង ពេលពោត កំពុងរៀបទុំ ។

**<u>ចំណាំ៖</u>** ដំណាំបណ្តាក់គ្នាគឺខុស ពីដំណាំដាំចម្រុះគ្នា (ឧទា. ដាំសណ្តែក តាមចន្លោះ ជួរពោត) ។ យើងមិនលើកទឹកចិត្ត ឲ្យដាំដំណាំលាយឡំគ្នានោះទេ ។

- **ដំណាំជីស្រស់ (ដំណាំគម្របដី)**

ដំណាំជីស្រស់នេះ ត្រូវបានគេដាំដើម្បីជាគម្របដី ហើយប៉ះប៉ូវជាតិអាសូត បង្កើន ជីវជាតិឲ្យដី ជួយទប់ស្កាត់ស្មៅ ការពារការបាក់ដី ជាចំណីសត្វប្រកបទៅដោយ ប្រូតេអ៊ីន និងផ្តល់ជាអាហារដល់មនុស្សផងដែរ។ គេបានអនុវត្តន៍ដាំដំណាំនេះ ហើយទទួលបានជោគជ័យអស់រយៈពេលជាច្រើនឆ្នាំកន្លងមកហើយ។ ការដាំ ដំណាំប្រភេទគឺ ស្មើនិងការធ្វើជីកំប៉ុស្តិ៍ដោយផ្ទាល់នៅក្នុងចម្ការ ហើយវាមិន ចាំបាច់ស្រោចទឹក និងប្រើកំលាំងពលកម្មច្រើន ដូចការធ្វើជីកំប៉ុស្តិ៍នោះទេ។ ដំណាំ ជីស្រស់នេះ សមស្របទៅនិង អាកាសធាតុ នៅតំបន់ភាគកណ្តាល និងភាគខាង លិច នៃទ្វីបអាហ្វ្រិក និងនៅតាមតំប់ន់ដែលមានភ្លៀងធ្លាក់ ត្រូវបានអូសបន្លាយ ដល់ចុងឆ្នាំ ជាការល្អគួរដាំដំណាំប្រភេទនេះ នៅរដូវមិនសូវមានទឹកភ្លៀង ដើម្បី ជួយកែសម្រួលដីត្រៀមសម្រាប់ដាំដំណាំសំខាន់។

ឧទាហរណ៍នៃដំណាំដែលងាយរលួយ ៖

- ពពួកលីហ្គោម(Legumes) ៖ សណ្តែកបាយ សណ្តែកគួរ សណ្តែកអង្គុយ សណ្តែកអាល់ហ្វាហ្វា។
- ម៉ូណូកូទីលេដូន ៖ ប្រភេទពូជស្រូវសាឡី(Wheat, rye, oats)។

សណ្តែកបាយ ត្រប់ក្រឡាញ់ និងស្រូវសាឡីក៏អាច ដាំជាដំណាំបណ្តាក់គ្នាបានដែរ។

# គោលការណ៍ណែនាំទូទៅនៃការផ្លាស់ប្តូរប្រភេទដំណាំ

| Alternative Crop guidelines (>600mm Rainfall) in hectares | | | | | | | | |
|---|---|---|---|---|---|---|---|---|
| **Crop** | | **Maize** | **Sunflower** | **Cotton** | **Sorghum** | **Soyabeans** | **Cow peas** | **Groundnuts** |
| **Planting technique** | | **Planting Stations** | | | **Furrow s** | | | |
| **Seed Rate** | kg/ha | 30 | 6 | 25 | 10 | 160 | 60 | 80 |
| **Spacing** | Rows | 75 | 75 | 75 | 75 | 75 | 75 | Split to 37.5 |
| | In-row | 60 | 60 | 60 | 10 | 5 | 10 | 8 |
| **Planting depth** | Cm | 5 | 2 | 2 | 2 | 1.5 | 2 | 3 |
| **Plant** | Seeds/hole | 3 | 3 | 5 | 1 | 1 | 1 | 1 |
| **Thin to** | Seeds/hole | 2 | 2 | 1-2 | 1 | 1 | 1 | 1 |
| **Population** | Plants/ha | 44 444 | 44 444 | 33 333 | 133 333 | 266 667 | 133 333 | 333 333 |
| **Target yield** | tons/ha | 5-7 | 2-2.5 | 2-2.5 | 2-2.5 | 1.5-2 | 1.5-2 | 1.5-2 |
| **Compost/Anthill/Manure** | Cup size ml | 350 | 350 | 350 | 350/m | 350/m | 350/m | 350/m |
| | 50 kg bags/ha | 156 | 156 | 156 | 94 | 94 | 94 | 188 |
| **or Compound Fertiliser** | Cup size ml | 12 | 8 | 8 | | 8/m | 5/m | 8/m |
| | Rate kg/ha | 293 | 196 | 196 | | 117 | 73 | 147 |
| **Top dress Fertiliser** | 1) Cup size ml | 8 | 5 | 5 | 12 | | | |
| | 2) Cup size ml | 5 | | | | | | |
| | Rate kg/ha | 246 | 94 | 94 | 136 | | | |
| **Woodash** | Cup size ml | 12 | | | | 12 /m | | 12 /m |
| | Rate kg/ha | 203 | | | | 136 | | 243 |
| **or Lime** | Cup size ml | 5 | | | | 5/m | | 5/m |
| | Rate kg/ha | 133 | | | | 80 | | 160 |

# សេចក្តីបន្ថែម

នៅក្នុងកសិកម្មតាមរបៀបព្រះជាម្ចាស់ យើងមានក្តីស្រមៃចង់ឃើញប្រជាជនក្រីក្របំផុតពី នឹមដែលគ្រប់សង្កត់ពួកគេ ហើយរស់នៅស្របតាមសក្តានុពលដែលព្រះជាម្ចាស់ ប្រទានអោយ ។

## អ្វីដែលព្រះគម្ពីបានលើកទឹកចិត្ត

អ្នកអាចចោទសួរថា " ចុះទូលបង្គំនេះជានរណាដែរព្រះអង្គ ? អ្នកគឺកូនប្រុស ស្រីរបស់ព្រះជាម្ចាស់ដែលជាព្រះដ៏ឧត្តម្ភ។ ព្រះយេស៊ូមានបន្ទូលថា ៖ យើងឃើញព្រះបិតាយើងធ្វើយ៉ាងណា យើងក៏ធ្វើយ៉ាងនោះដែរ។ យើងស្តាប់លឺបិតាយើង មានបន្ទូលបែបណា យើងក៏ធ្វើតាមបែបនោះដែរ។ ដូច្នេះហើយ បានជាយើងចង់ធ្វើ តាមគំរូដែលព្រះយេស៊ូបានបង្ហាញយើង។ ព្រះអង្គយាងមកដើម្បីបម្រើ បង្ហាញផ្លូវដល់ជនក្រីក្រ អ្នកមានជម្ងឺ អ្នកខ្វេចខ្វាំចិត្ត និងអ្នកទន់ទាប ឲ្យទទួលបានការសង្គ្រោះនិងរស់នៅក្នុងជីវិតបរិបូរណ៌ស្របតាម ព្រះបន្ទូលសន្យារបស់ព្រះអង្គ។ យើងមានឱកាសមួយដ៏អស្ចារ្យក្នុងការធ្វើរឿងនេះតាមរយៈការប្រើប្រាស់ **កសិកម្មតាមរបៀបព្រះជាម្ចាស់** ដើម្បីបំពេញតាមបេសកម្មនៃ **ព្រះគម្ពី អេសាយជំពូក ៥៨** ដែលយើងជាមនុស្សព្រះជាម្ចាស់បានជ្រើសរើស។ នេះគឺជាអភ័យឯកសិទ្ធិមួយ ក្នុងការបម្រើដល់ស្តេចដ៏អស្ចារ្យ ( ម៉ាថាយជំពូក ២៥; ៣៥ )និងរស់នៅក្នុង ព្រះពររបស់ព្រះអង្គរនៅ ពេលយើងជួយយកអសារដល់អ្នកក្រីក្រ និងអ្នកគ្មានទីពឹង ។

## វាផ្តើមចេញពីអ្នក

ប្រសិនបើអ្នកចង់ អនុវត្តន៍កសិកម្ម **តាមរបៀបព្រះជាម្ចាស់** សូមសិក្សាពីរបៀបធ្វើឲ្យបានល្អិតល្អន់ ។ ចូរចាប់ផ្តើមចេញពីចំណុចតូច រួចពង្រីកវាឲ្យធំដោយក្តីស្មោះត្រង់

បន្តសិក្សាស្វែងយល់ពី សម្ភារៈដែលយើងប្រើ និងចូលរួមវគ្គបណ្តុះបណ្តាលជារឿយៗ ។

ប្រសិនបើអ្នកចង់ក្លាយ ជាគ្រូបណ្តុះបណ្តាលដែល មានការទទួលស្គាល់ អ្នកត្រូវមានការប្តេជ្ញាចិត្ត ចូលរួមដំណើរការបំពាក់បំប៉នរបស់យើង ។

**ជារួមមាន៖**

- ចូលរួមវគ្គបណ្តុះបណ្តាលយ៉ាងតិច ៣ដង
- ហេតុផលមួយដែលសំខាន់នោះ អ្នកគួរតែដាំហើយនឹងគ្រប់គ្រងសួនគំរូរបស់អ្នកក្បែរប្រភពទឹក។
- សូមចូលរួមនៅពេលដែលមាន ដំណើរបេសកកម្មចុះណែនាំដោយផ្ទាល់នៅចម្ការដំណាំម្តងៗ។
- នៅពេលគ្រូបណ្តុះបណ្តាលថ្នាក់លើ យល់ថាអ្នករួចរាល់ហើយ យើងនឹងផ្តល់សិទ្ធិឲ្យ អ្នកក្លាយជាគ្រូបង្រៀន កសិកម្មតាមរបៀបព្រះជាម្ចាស់ ដោយមានការទទួលស្គាល់ ។

ត្រូវចាំថា **កសិកម្មតាមរបៀបព្រះជាម្ចាស់** មិនមែនជាអង្គការនោះទេ តែវាជាចំណេះដឹងសម្រាប់បម្រើដល់រូបកាយរបស់ព្រះគ្រីស្ទ។ យើងមិនកំពុងព្យាយាមអូសទាញអ្នកឲ្យចូលក្នុងក្រុមកសិកម្មតាមរបៀបព្រះជាម្ចាស់នោះទេ តែវាជាការផ្តល់ចំនេះដឹងនិងចេះយកទៅប្រើប្រាស់ក្នុងសហគមន៍របស់អ្នក។ យើងចង់បញ្ជោញគ្រូបណ្តុះបណ្តាលរាប់ពាន់ អ្នកដោយធ្វើការចំណុះក្រុមជុំនុំ បេសកកម្ម និងអង្គការរបស់ ពួកគេដើម្បីជួយនាំសារនេះដែលជាសារនៃ ក្តីសង្ឃឹមដល់មនុស្សជាច្រើន ។

**ការអនុវត្តន៍ចម្ការគំរូ ដែលមានទឹកគ្រប់គ្រាន់**

ចម្ការគំរូ គឺជាយន្តការមួយជួយអនុវត្តន៍ **កសិកម្មតាមរបៀបព្រះជាម្ចាស់** ឲ្យមានប្រសិទ្ធិភាព។ ចម្ការគំរូមានទំហំ ៦ម .× ៦ម រៀបចំឡើង ដើម្បីជាការបង្ហាញងាយដល់

ការបណ្តុះបណ្តាល និងបង្រៀនសិស្ស នៅក្នុងសហគមន៍។ វាជួយសន្សំសំចៃ និងធ្វើឆាប់ហើយ គឺចំណាយពេលត្រឹម ២ ទៅ ៣ម៉ោង។ ទោះបីចម្ការនេះតូចក៏ដោយ ក៏វាមានទំហំធំ ល្មម ក្នុងការបង្រៀនកសិករ ពីរបៀបអនុវត្តន៍បច្ចេកទេស កសិកកម្មតាមរបៀបព្រះជាម្ចាស់ដោយជោគជ័យ។

ចម្ការនេះជួយឲ្យសិស្ស មើលឃើញច្បាស់ ឃើញម្តងហើយម្តងទៀត និងមានឱកាសក្នុងការអនុវត្តន៍ដោយខ្លួនឯង។ វាជាការបង្ហាញមួយដែលមានសកម្មភាពឆ្លើយឆ្លង និងបង្កើតបរិយាកាសសប្បាយរីករាយដល់អ្នកដែលចូលរួម។ ព័ត៌មានលម្អិតនិយាយអំពីការអនុវត្តន៍ ចម្ការគំរូ សូមមើលនៅក្នុងខ្សែរវីដេអូ និង សេចក្តីណែនាំ ពីរបៀបបង្រៀន ។

**គន្លឹះសម្រាប់ជោគជ័យក្នុងការអនុវត្តន៍នៅតាមសហគមន៍**

- ត្រូវការប្តេជ្ញាចិត្ត ចូលរួមវគ្គបណ្តុះបណ្តាលដដែលៗ ៥/៦ ដងក្នុង ១ឆ្នាំ
- ស្វែងរកមនុស្សដែលជាគន្លឹះសំខាន់
- ផ្តល់ជូនគ្រប់គ្នាគ្មានការប្រកាន់បក្សពួក
- មានដីចម្ការត្រៀម ទុកពង្រីកបន្ថែម (យកទំហំប៉ុនចម្ការគំរូ)
- ប្រសិនសហគមន៍ ដែលអ្នកបង្រៀននៅក្បែរផ្ទះរបស់អ្នក ចូរបំបែកវគ្គបង្រៀន ទៅជាតូចៗ តាមដំណាក់កាលខុសៗគ្នានៃដំណាំ
- ត្រូវបង្រៀន ឲ្យត្រូវតាមរដូវកាលនៃឆ្នាំ
- ត្រូវបែងចែក បងប្អូនកសិករទៅជាក្រុមតូចៗ
- មិនត្រូវចែកជា អំណោយលើកទឹកចិត្ត ឬគ្រាប់ពូជ ឬជី
- ពេលវាស់វែង ដីគឺជាពេលមួយដ៏ល្អ ក្នុងការបង្រៀនដល់ បងប្អូនកសិករ
- អធិស្ឋាន

## សេចក្ដីសន្និដ្ឋាន

*នៅពេលកសិកម្ម តាមរបៀបព្រះជាម្ចាស់ រីកសុះសាយកាន់តែធំ ដល់ជាតិសាសន៍ផ្សេងៗ យើងសូមលើកទឹកចិត្តឲ្យអ្នកចាំថា គោលដៅនៃកសិកម្មនេះគឺដើម្បីជួយសម្រាលទុក្ខ និងជួយបងប្អូនកសិករអោយងាកចេញពីភាពក្រីក្រ ត្បិតព្រះជាម្ចាស់ស្រលាញ់និងយកចិត្តទុកដាក់ដល់ពួកគាត់ ដូចនេះចូរយើងផ្ដោតទៅលើការជួយជ្រុំជ្រែង និងបម្រើពួកគាត់ឲ្យអស់ពីចិត្ត។*

*សូមយើងជួយនាំសារនេះ ដោយការស្ដាប់បង្គាប់ព្រះបន្ទូល ដោយចិត្តអាណិតអាសូរដូចព្រះគ្រីស្ទ ហើយយកវាទៅចែកចាយដោយក្ដីស្រឡាញ់ ទៅកាន់ បងប្អូនដែលក្រក្នុងចំណោមអ្នកក្រដើម្បីឲ្យពួកគាត់មានសេរីភាពរួចផុតពីនឹមនៃភាពក្រីក្រ ។*

# ប្រភពធនធាន

- គេហទំព័រ កសិកម្មតាមរបៀបព្រះជាម្ចាស់ www.farming-gods-way.org
- ខ្សែរវីដេអូ កសិកម្មតាមរបៀបព្រះជាម្ចាស់ វីដេអូនេះ បង្ហាញពីខគម្ពីសំខាន់ៗ ក្នុងកសិកម្មតាមរបៀបព្រះជាម្ចាស់ របៀបអនុវត្តន៍ ជាក់ស្តែងទាំងខាងបច្ចេកវិទ្យា និងការគ្រប់គ្រង ។ វីដេអូនេះគឺធ្វើឡើងដោយ មានដាក់ជារូបភាពគំនូរជីវចល រូបភាពក្រាហ្វិក បង្ហាញពីទីតាំងលើចម្ការពិតប្រាក៏ដ ដើម្បីជាព័ត៌មានលំអិត។ តាមរយៈខ្សែរវីដេអូ ៧ ម៉ោងនេះ អ្នកនិងមើលឃើញពីស្នាព្រះហ័ស្ត បង្កើតដ៏អស្ចារ្យរបស់ ព្រះជាម្ចាស់និងអំណោយទាន ដែលព្រះអង្គប្រទាន នៅក្នុងវិស័យកសិកម្មតាមរបៀបព្រះអង្គ ។
- ឯកសារយោងសម្រាប់គ្រូបង្រៀន៖ នេះជាធនធានមួយដ៏មានប្រយោជន៍ សម្រាប់អ្នកដែលចង់ពង្រីក ចំណេះដឹង បន្ថែមលើកសិកម្មតាមរបៀបព្រះជាម្ចាស់។ ប្រសិនបើ បើអ្នកប្រាថ្នាចង់បង្រៀនកសិកម្មតាមរបៀប ព្រះជាម្ចាស់ អ្នកគួរតែមានឯកសារនេះនៅក្នុងដៃ ។
- កូនសៀវភៅណែនាំពីវិធី ធ្វើកសិកម្មតាមរបៀបព្រះជាម្ចាស់៖ កូនសៀវភៅនេះបង្ហាញ ពីរបៀបធ្វើ ជាពិសេសពេលបង្រៀនដល់សហគមន៍ ។ អ្នកអាចទាញយក ឯកសានេះបានពីគេហទំព័រ កសិកម្មតាមរបៀបព្រះជាម្ចាស់។ កូនសៀវភៅនេះត្រូវ បានបកប្រែជាភាសាផ្សេងៗហើយអ្នកអាចទាញយកឯកសារបកប្រែនេះ បាននៅលើពាក្យថា ធនធាន ពេលគេបកប្រែវាចប់សព្វគ្រប់ ។
- សាកសួរព័ត៌មានទូទៅតាមរយៈអ៊ីម៉ែល info@farming-gods-way-org